ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ២ លេខ ៦
N° 6

Février

ខែ កុម្ភៈ ព.ស. ២៤៩៣

ឆ្នាំសិក្សា ១៩៥០ - ៥១
1950 - 51

TIONALE
AMBODGE
K - 2
-1951
61

# ព្រះរាជអាណាចក្រកម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

## ទស្សនាវដ្ដី សម្រាប់ គ្រូបង្រៀន

## បញ្ជីរឿង

ទំព័រ

ឧត្តមដ្ឋាន ភាសា ៣
មជ្ឈិមដ្ឋានទី ២ - មជ្ឈិមដ្ឋានទី ១ ភាសា ៨
អាទិកដ្ឋាន ភាសា ១៣
កុមារដ្ឋាន ភាសា ២៥
បរិវច្ឆណាដ្ឋាន ភាសា ២៩
មជ្ឈិមដ្ឋានទី២-ឧត្តមដ្ឋានទឹងនព្វន្ត-រង្វាស់រង្វាល់-ធរណីមាណសាស្ត្រ ៣៤
អាទិកដ្ឋាន នព្វន្ត - ៤១
មជ្ឈិមដ្ឋានទី ១ - នព្វន្ត - រង្វាស់រង្វាល់ -ធរណីមាណសាស្ត្រ ៤៧
បរិវច្ឆណាដ្ឋាន - នព្វន្ត - រង្វាស់រង្វាល់ ៥៤
កុមារដ្ឋាន - នព្វន្ត - រង្វាស់រង្វាល់ ៥៨
មជ្ឈិមដ្ឋានទី ២ - ឧត្តមដ្ឋាន - វិទ្យាសាស្ត្រ - វិធីបង្ការរោគ ៦៤
អាទិកដ្ឋាន - មជ្ឈិមដ្ឋានទី ១ - វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ. ៧៧
កុមារដ្ឋាន - វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ ៨៦
បរិវច្ឆណាដ្ឋាន - វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ ៩២
លោកនីតិ - មេសូត្រតែមាត់ ៩៨

# ឧត្តមញ្ញាន

## ល្បែងប្រណាំងទូកង

ល្បែងប្រណាំងទូកនេះ ជាល្បែងសម្រាប់លេងកំសាន្តមួយ យ៉ាងឧឡារិក របស់ជនជាតិខ្មែរ ចាស់-ក្មេង-ប្រុស-ស្រី គេទុកជាទំនៀមទម្លាប់ ខាងល្បែងមួយដ៏ប្រសើរ របស់ជនជាតិខ្មែរ តាំងពីបុរាណសម័យ រហូតមកដល់សព្វថ្ងៃនេះ ក៏មាននិយមលេងជាច្រើន រាល់ខែត្រ, រាល់ស្រុក ក្នុងដែនកម្ពុជានេះ ។ មិនតែប៉ុណ្ណោះសោត សូម្បីជនជាតិដទៃ ដូចយ៉ាងជនជាតិចាម-ជ្វា ជាដើម ក៏ចូលចិត្តលេងប្រណាំងទូកដូចខ្មែរយើងដែរ ។

ឯការលេងប្រណាំងទូកនេះ ជនជាតិខ្មែរច្រើនតែប្រណាំងគ្នាល់គ្នា នៅរដូវវស្សា ដែលទឹកឡើងលិចព្នាបលិចសព្វទីភូមិឋាន ។

ក្នុងថ្ងៃបុណ្យភ្ជុំបិណ្ឌម្តងៗ មហាជនជាតិខ្មែរទាំងក្មេង-ចាស់ ប្រុស-ស្រី គេនាំប្រមូលគ្នារើសរកទូកប្រណាំងយ៉ាងលឿន ហើយហៅគូគេ ដាក់បំណាំឲ្យស្មើគ្នា បើទូកម្ខាងមានគ្នា ២០ នាក់ ទូកម្ខាងក៏ត្រូវឲ្យមានគ្នា ២០ នាក់ដែរ ឬលើសខ្វះពីគ្នាបន្តិចបន្តួចក៏គេសុខចិត្តព្រមលេង តែគេ

ប្រើឲ្យពួកកុមារីនៅក្រមុំពេញជំទង់ អង្គុយខ្ទង់ទូកខាងមុខ ពួកកុមារ អង្គុយខ្ទង់ទូកខាងក្រោយ ហើយអ្នកកាច់ចង្កូតទូកប្រណាំងនោះ គេប្រើនយកប្រពធំដៃវែងមកកាច់ចង្កូតទូកផង ឯអ្នកក្រៅពីនោះកាន់ប្រវាគ្រប់ដៃរៀងៗខ្លួន ហើយមានម្នាក់ទៀតហៅថាគ្រូបង់បត់ ឬអ្នកមានសំដីថ្មី មាត់គ្រាន់បើ អង្គុយលុតជង្គង់ត្រង់ប្រចកក្បាលទូក អ្នកនេះ កាន់ប្រវាលនយ៉ាងល្អ ហើយផ្គួតក្បាលផង សម្រាប់ស្រែកយកជ័យ ឬស្រែកថា "មួយយ៉ូ ៗ" ក្នុងកាលដែលកំពុងប្រណាំងគ្នា ៗ

ពាក្យពន្យល់ .-

ឧឡារិក = រុងរឿង, ហ៊ឹកហ៊ាក់

បុរាណសម័យ = សម័យជាន់ដើម, ជំនាន់បុព្វបុរសរបស់យើង ៗ

និយម = កាប់អាន , អនុលោមតាមធម្មតា

ផ្លូវវិស្វា (ឬវិស្វានផ្លូវ) = ផ្លូវមានក្បៀនថ្នាក់

រៀនពាក្យ .-

ជាតិដទៃ ឬ ជនជាតិបរទេស

កុមារីពេញជំទង់ ឬ យុវតី , មាណវិ

# លោកនាយពលនឹងឪពុក

គ្រានោះព្រះមហាកជាក្រុងជប៉ុនដាក់អាជ្ញាឲ្យសម្លាប់នៅក្នុងក្រុងនរណាដែលមានជន្មវស្សាលើសពីសែសិបឡើងទៅ ទាំងប៉ុន្មាន ៗ នោះ ជនណាដែលមានអាយុដល់កំរិតបញ្ញត្តិ ក៏រត់ចេញទៅពួនលាក់ខ្លួនឯងក្រៅក្រុង ប៉ុន្តែនាយពលម្នាក់ឯងពុំចង់ឃ្លាតពីឪពុកម្តាយដែលមានអាយុ ៧០ ឆ្នាំហើយ ទើបជីកអុងម៉ុងលាក់ឪពុកម្តាយនៅក្រោមផ្ទះ ។

ក្នុងខណៈនោះ ព្រះចៅក្រុងចិនចោទប្រស្នាបញ្ហាឲ្យព្រះមហាកជាក្រុងជប៉ុនដោះ ដើម្បីចង់ដឹងថាជាមនុស្សមានប្រាជ្ញាឬទេ ។ ក្នុងបញ្ហានោះព្រះចៅក្រុងចិនបញ្ជូនឈើមួយកំណាត់ប្រវែង ៦០ សង់ទីម៉ែត្រក្រឡឹងស្អាតក្បាលមូលទាំងសងខាង មកឲ្យព្រះមហាកជាជប៉ុនទាយថាខាងណាចុង ខាងណាគល់ ៗ អ្នកចេះដឹងទាំងឡាយចេះតែទាយស្មាន ៗ ទៅ ។ នោះឪពុកនាយពលប្រាប់នាយពលថា: "ចូរកូនឯងដាក់កំណាត់ឈើនោះបណ្តែតលើទឹកហូរ បើចុងខាងណាផាកទៅបណ្តោយខ្សែទឹក គឺខាងនុះឯងជាគល់ ព្រោះគល់ធ្ងន់ជាងទើបវាផាកចុះតាមខ្សែទឹក" នាយពលទៅធ្វើតាមដំបូន្មានឪពុកចំពោះព្រះភក្ត្រ ទីងមុខសេរ-

កាមាត្យតាំងតួង រួចដៅសំគាល់ជាក្បួរ ថា "គល់" ហើយបញ្ជូនទៅ ថ្វាយព្រះចៅក្រុងចិនវិញ ។ ព្រះចៅក្រុងចិនក៏ទទួលថាត្រូវហើយ ។ ក្រោយបន្តិចមកទៀត ព្រះចៅក្រុងចិនឲ្យយកដុំថ្មកណ្ដៀងដែលចោះរន្ធវិលជុំវិញប្រាំពីរជុំ ហើយបញ្ជូនមកព្រះមហាក្សត្រជប៉ុន ប្រាប់ថាឲ្យយកខ្សែមួយសរសៃដោតតាមរន្ធនោះឲ្យលេចពីម្ខាងទៅម្ខាង ។ ក្នុងបញ្ហានេះគ្មាននរណាអាចដោះបានឡើយ ។ នោះឪពុកនៃនាយពលប្រាប់កូនថា: "ចូរកូនឯងរកស្រមោចធំ ៗ ឲ្យបានពីរ រួចយកខ្សែសចងខ្លួនវានៅចុងខ្សែ រួចដាក់ស្រមោចទាំងពីរនោះទៅក្នុងរន្ធ យកទឹកឃ្មុំលាបមាត់រន្ធម្ខាង ។ លុះស្រមោចធុំក្លិនទឹកឃ្មុំ វានឹងសុលចេញតាមរន្ធនាំខ្សែមករកទឹកឃ្មុំ ។ លោកនាយពលក៏ធ្វើតាមដំបូន្មានហើយបានសម្រេចដូចប្រាថ្នា ។ ស្ដេចក្រុងចិនយល់ឃើញថាស្រុកជប៉ុនមានអ្នកប្រាជ្ញ ក៏លែងចោទប្រស្នាទៀតឡើយ ។ ដើម្បីនឹងប្រទានរង្វាន់ឲ្យសមគុណបំណាច់ ព្រះមហាក្សត្រាធិរាជសួរនាយពលថា: "លោកនាយពល លោកចង់បានសក្តិយសដូចម្ដេចយើងនឹងឲ្យតាមចិត្ត" ។ លោកនាយពលទូលតបថា: "ខ្ញុំទូលបង្គំមិនប្រាថ្នាយសសក្តិឡើយ បុំន្តែប្រាស

ប្រទានអនុញ្ញាតឲ្យទូលបង្គំនៅជាមួយនឹងមាតាបិតាចាស់ជរាប៉ុណ្ណោះឯង ”

ព្រះមហាកដាទ្រង់ប្រទាន មិនតែប៉ុណ្ណោះ ទ្រង់ឲ្យលើកលែងញាតិសន្តាន ដែលគេចេញពីក្រុងនោះផង ។

ពន្យល់ពាក្យ .–

អាជ្ញា = បញ្ញត្តិ អំណាច

អុងម៉ុង = រូងកន្ដី, ទំពួនកន្ដី,

នាយពល = មេទាហាន

ប្រស្នា បញ្ហា = អាថ៌កំបាំង ពាក្យដែលមានសេចក្ដីឲ្យពិចារណា

សេវកាមាត្យ = មុខមន្ត្រី

ពល = កម្លាំង, ទាហាន

រៀនពាក្យ .– (សទិសនាម)

លាក់ (កិរិយា) = បំពួនកុំឲ្យគេឃើញ

លក្ខណ៍ ឬ លក្ស្មណ៍ (នាម) = លំអសម្រាប់រូប ; គេហៅ មនុស្សមានលក្ខណ៍, ស្ត្រីគ្រប់លក្ខណ៍ ។

ល័ក្ត ឬ ល័ខ = ជ័រខះរឹងកើតពីសត្វល្អិត, ល័ខស្វាយ

ភក្ត្រ (នាម) = មុខ

ភក្តិ (នាម) = គ្រប់គ្រង , មិត្តភក្តិ

ភក្ស ភក្សា = អាហារ

---

## មជ្ឈិមដ្ឋាន ទី ២

## យើងត្រូវបើកបង្អួច

គេហដ្ឋានដែលយើងស្ថិតនៅជាប្រក្រតី ទោះជាមានសភាពយ៉ាងដូចម្ដេចក្តី, ទោះបីគេហស្ថាននោះធំក្តី តូចក្តី, ជាផ្ទះមានដំឡៃយ៉ាងសុក-ស្តម្ភ ឬភាពជាទីទ្រុះទ្រោយក្តី យើងត្រូវតែរៀបចំឲ្យមានបង្អួចធំទូលាយ ដើម្បីឲ្យពន្លឺព្រះអាទិត្យដែលជាទីរភាយធាតុអាកាសបរិសុទ្ធ ចេញចូលបានដោយបរិបូណ៌ ។ ពន្លឺព្រះអាទិត្យនឹងខ្យល់អាកាសនេះ ជាធនធានមានដំឡៃ ដែលផ្ទះក្រីក្រ ងាយរកបានមិនពិបាក ហើយធនធានមានដំឡៃតែប៉ុណ្ណោះនេះ ប្រសើរជាជាងធនធានដទៃទៀតជាច្រើនភាគ ដោយហេតុជួយទ្រទ្រង់អនាម័យនឹងជីវិតឲ្យបានគង់វង់តទៅ ។

មានពាក្យបុរាណពោលថា: " នៅទីដំបន់ណាដែលពន្លឺព្រះអាទិត្យចូលទៅពុំដល់ គ្រូពេទ្យគង់នឹងចូលទៅទីនោះពុំខាន" ។ ដើមផ្កាតូច ៗ ស្មៅទាំងឡាយដែលដុះក្នុងបំការ រុក្ខជាតិគ្រប់យ៉ាង ពុំអាច

នឹងលូតលាស់ទៅរួចបានឡើយ ត្រូវមានពន្លឺព្រះអាទិត្យទើបរុក្ខជាតិទាំងនោះ លូតលាស់មានផ្លែផ្កាបាន ។ ឯជាតិមនុស្សយើងក៏ដូច្នោះដែរ ដើម្បីនឹងរស់រានមានជីវិត យើងត្រូវការពន្លឺព្រះអាទិត្យនៅក្នុងម្លប់នឹងទីងងឹត រុក្ខជាតិនឹងស្រពោនស្វិត ក្រៀមក្រោះ ហើយស្លាប់វិនាសពុំខាន ។

ពាក្យសួរ :—

ហេតុអ្វីបានជាយើងត្រូវបើកបង្អួចឲ្យធំទូលាយ ?

ហេតុអ្វីបានជាព្រះអាទិត្យនឹងធាតុអាកាសល្អបរិសុទ្ធ មានដំឡៃយ៉ាងប្រសើរលើសធនធានដំឡៃឯទៀតជាច្រើនភាគ ?

ហេតុអ្វីបានជាពោលថា : "កន្លែងណាដែលពន្លឺព្រះអាទិត្យចូលទៅពុំដល់ គ្រូពេទ្យគង់នឹងចូល" ?

រុក្ខជាតិទាំងឡាយ បើនៅក្នុងម្លប់នឹងទីងងឹត តើនឹងប្រែទៅជាយ៉ាងដូចម្តេច? ។

---

## រឿងផ្ទាំងវែងអន្ទង់វែង

មានបុរសពីរនាក់ជាប្តីប្រពន្ធ ក្នុងថ្ងៃមួយប្តីចេញទៅរកចាប់បានអន្ទង់មួយ យកមកធ្វើជាអាហារ ហើយបានយកមកឲ្យប្រពន្ធ ប្រាប់ថា "ឯង

យកអន្ទង់នេះទៅស្ងោរស៊ី" ប្រពន្ធឆ្លើយតបទៅប្ដីវិញថា "ចុះបើអន្ទង់នេះវែងម្ល៉េះ បានឆ្នាំងវែងពីណា នឹងយកមកស្ងោរអន្ទង់នេះបាន" ប្ដីស្ដាប់ហើយក៏នឹកក្នុងចិត្តថា "ប្រពន្ធអញល្ងង់អ្វីម្ល៉េះ" ហើយប្រាប់ប្រពន្ធថា បើឯងរកឆ្នាំងវែងគ្មានទេ ឯងយកអន្ទង់នោះទៅព្យួរទុកទៅ" រួចប្រពន្ធនោះក៏គេចទៅដេកបំបៅកូននៅក្នុងមុងទៅ ប្ដីក៏យកអន្ទង់មកកាប់ចិញ្ច្រាំ ហើយយកឆ្នាំងមកដាក់ស្ងកក្ខូរ លុះឆ្អិនក៏តាំងដោះដួសរួច ហៅប្រពន្ធឲ្យមកស៊ី ៗ រួចក៏លាងចានទុកដាក់ទៅ តែឆ្នាំងនោះនៅសល់សម្អន្ទង់បន្តិចៗបាតឆ្នាំង ប្ដីក៏មិនលាងឆ្នាំងនោះទេ ហើយចេញទៅក្ដួរស្រែបាត់ទៅ ៗ ឯប្រពន្ធដឹងថា "ប្ដីចេញទៅបាត់ហើយក៏ងកមើលដប់សម្អន្ទង់ដែលធ្លាក់នោះ" ក៏ស្ទុះទៅយកឆ្នាំងមកលិទ្ធ ដល់ចំលិទ្ធណាស់ទៅ ក្បាលនាងប្រពន្ធនោះចូលទៅក្នុងឆ្នាំង ៗ គ្របជាប់ពីលើ មិនដឹងធ្វើដូចម្ដេចនឹងយកឆ្នាំងនោះបាន ក៏រត់ទៅពួននៅក្នុងមុង លុះប្ដីត្រឡប់មកពីក្ដួរស្រែវិញ រកប្រពន្ធពុំឃើញក៏ស្រែកហៅ ៗ ទៅឮសូរឆ្លើយសំឡេងនោះក្រវល់ហាក់ដូចជាចំឡែកណាស់ ប្ដីដើររកមើលមិនឃើញ ក៏ចូលទៅបើកមុងមើល បានឃើញប្រពន្ធជាប់ក្បាលនៅក្នុងឆ្នាំង ទើបរកដំបងវាយឆ្នាំងនោះ បំបែកទៅ ប្រពន្ធ

ស្រែកប្រាប់ថា" យោះ! អញ្ចួន មិនគាត់ឯងសោះ "ប្ដូនក៏អស់សំណើច ក៏ដើរចេញទៅ ។

---

# មជ្ឈិមដ្ឋានទី១

## រៀនមើល - ពាក្យ - ភាសា

### រឿងតាភោកនឹងក្មេងវត្ត (ត)

ឯកូនក្មេងវត្តកាលដល់ពេលរៀមកជុំគ្នា បានឃើញតាភោកមកទូលលោកឲ្យដេរវាយរាំផ្ទះគ្នា វាក៏ជុំគ្នាថាពួកយើងទៅបេះផ្លែធៀវតាភោក ពីព្រឹកមិញ ឥឡូវគាត់មកពិតលោកគ្រូឲ្យវាយពួកយើងហើយ លោកគ្រូថាចាំពួកយើងមកជុំគ្នាកាលណា លោកនឹងវាយឲ្យគាត់ប្រាកដហើយ អើហ៊ុយ គនយើងឥឡូវតាភោកជាប់ជនិយាយប្រាជ្ញក្រោកនឹងលោកគ្រូយើង ផ្ទះគាត់ស្ងាត់គ្មាននរណានៅទេ យើងបេះមុនក៏ដូចជាបេះក្រោយដែរ ។ ពួកក្មេងនិយាយប្រឹក្សាយល់ព្រមគ្នាហើយ ទើបនាំគ្នាហែករបងកន្ទួងចូលទៅដល់ដើមធៀរ ហើយឡើងបេះស៊ីខ្លះ ស្ពាយយកទៅវត្តខ្លះ ខ្លះបុក ខ្លះកាវ ខ្លះអញ្ជើញឲ្យគ្នារើសរៀប រើសស៊ីតាមចិត្តទទៃ ។

លុះល្ងាចទើបនាំគ្នាទៅវត្ត ។ ឯតាគោក លុះដល់ពេលល្ងាចហើយ ក៏ថ្វាយបង្គំលាលោកគ្រូចៅអធិការវិលទៅគេហស្ថានវិញ បានឃើញសំបកផ្លៀវទឹងផ្លែចាស់ខ្ចីជ្រុះខ្ជាំនៅខាងផ្ទះខ្លួនដូច្នោះ ក៏រឹងរិតតែខឹងស្តាយរបស់ខ្លួនក្រៃពេក កើតក្តៅក្រហាយចិត្តដ្បិតខ្លួនទៅនិយាយលេងហួសការ គ្មាននរណាទៅរក្សាផ្ទះរក្សាដំណាំដូងខ្លួន ជាទីឱកាសឲ្យអាក្មេងវត្តមកបេះបោចបុកបែនលើសលែងកាលជាន់មុនៗ ទឹងទៅពិតលោកឲ្យដេរ៉ាយម្តងទៀតក៏ផុតកាល គឺកាលមុនបានទៅពិតដល់លោកហើយ លោកមិនទាន់បានដេរ៉ាយប្រដៅឲ្យឯងផង តាគោក គិតរកផ្លូវធ្វើក្មេងពុំបានក៏ខឹងរំខានក្តៅចិត្តក្រៃពេកហោង ។

ពន្យល់ពាក្យ.– ជំនុំគ្នា=គិតគ្នា ។ ល្ងាច = សាយណ្ហសម័យ (ពេលពីថ្ងៃត្រង់ទៅព្រលប់) ។ គេហស្ថាន =ផ្ទះលំនៅ ។ ជ្រុះខ្ជាំ = ជ្រុះពាសពេញ ។ ក្តៅក្រហាយចិត្ត= ខឹងពេលពលក្នុងចិត្ត ។ ហួសការ= ជ្រុលពេល ។ ផុតកាល = អស់វេលា ។

ពាក្យសួរ.– ក្មេងវត្តជំនុំគ្នាថាដូចម្តេច ? – លុះប្រឹក្សាព្រមគ្នាហើយ វាធ្វើដូចម្តេច ? – ក្មេងវត្តបេះបំផ្លាញផ្លែឈើតាគោក

ទាំងពីរលើកនេះលើកណាដែលអ្នកយះច្រើនជាង ? កាលបើឃើញផ្ទៃឈើគាត់ជ្រុះខ្ចាំនៅលើផែនដីដូច្នោះ តើគាត់គិតដូចម្តេច? គាត់មានក្តីក្តៅក្រហាយយ៉ាងណា ? អ្នកយល់ឃើញដូចម្តេចក្នុងរឿងនេះ ? ។

## សរសេរតាមសូត្ររៀបចំ

សុំឲ្យយករឿងរៀនមើលមកធ្វើ

សរសេរពាក្យពិបាក ·– បេះ (ះ) ផ្សៀវ (ផ្ស) ·ច្រាកដ (ដ) ច្រាជ្រ (ជ្រ) - នរណា (នរ) ប្រឹក្សា (ប្រឹ -ក្សា) អង្រួន (អង់រួន) បិត្ត (ត្ត) គេហស្ថានឬគេហដ្ឋាន (ស្ថា = ឋា) វក្សា (ក្សា) ។

---

# អាទិកដ្ឋាន

## បង្រៀនពាក្យ–ហាត់ភាសា

អាទិត្យទី១.– ផ្ទឹង (អង្គសន្ធលិក)

នាម.– ផ្ទឹងខ្នង ផ្ទឹងជំនីរ ផ្ទឹងលលាដ៍ក្បាល ផ្ទឹងស្មាបប្រជៀវ

ឆ្អឹងជង់កាំបិត ឆ្អឹងដៃជើង ឆ្អឹងម្រាមដៃ-ម្រាមជើង ឆ្អឹងដើមដៃ ឆ្អឹងកំភួនដៃ ឆ្អឹងភ្លៅ ឆ្អឹងកំភួនជើង ឆ្អឹងត្រគាក

គុណនាម.- មូល សំប៉ែត វែង ខ្លី រឹង កោង ត្រង់ រដិបរដុប

កិរិយាសព្ទ.- បាក់ដៃ-ជើង កាត់ដៃ-ជើង បែកលលាដ៍ក្បាល ដកម្រាម-ដៃ-ជើង ។

ហាត់ភាសា.- ឆ្អឹងក្នុងខ្លួនយើងទាំងប៉ុន្មានប្រមូលមកហៅថាអ្វី? នៅដៃ ជើងមានឆ្អឹងអ្វីខ្លះ? អ្នកស្គាល់ឆ្អឹងវែង-ខ្លីអ្វីខ្លះ? គេមានប៉ុន្មានយ៉ាង? ឆ្អឹងជំនីមានប៉ុន្មាន? រាងដូចម្ដេច? ឆ្អឹងលលាដ៍ក្បាលយ៉ាងដូចម្ដេច? យើងឈរត្រង់បានដោយសារអ្វី? (ឆ្អឹងខ្នង) – ឆ្អឹងមេដៃ-ជើងមានប៉ុន្មានចំណែក? ឆ្អឹងម្រាមដៃ-ជើងមានប៉ុន្មានចំណែក ? ។

ការហាត់សរសេរ.- ចូរបំពេញឃ្លានៅកន្លែងចន្លោះខាងក្រោមនេះ ៖ រូបមនុស្សយើងមានអវយវ .... អវយវលើនីមួយៗ មកភ្ជាប់នឹងដងខ្លួននៅស្មា ឯស្មានេះមានឆ្អឹងពីរ ឆ្អឹងក្រោយហៅថា ....ឯឆ្អឹងខាងមុខហៅថា ... អវយវក្រោមនីមួយ ៗ មកប្រសព្វភ្ជាប់គ្នា ខាងក្រោយត្រង់កន្លែងចុង ....ឆ្អឹងលលាដ៍ក្បាល - ....។ មានឆ្អឹងខ្លះវែងគឺដូច....។

## បង្រៀនមើល

### ឆ្អឹងសន្លាក់ឬគណ្ឋិក

សៀវភៅវត្ថុស្វាធ្យាយន៍អាទិកដ្ឋានទំព័រ ៩ - ១០

អានពាក្យ.— អចលគណ្ឋិក = ( អ : ច : ល៉ : គ័នថិក : )

កែតម្រូវពាក្យ.— ដឹកប = ដកប = ។ គរ = គ ។

មឹន=មិន ។ ប្រសប់គ្នា=ប្រសព្វគ្នា ។

## សរសេរតាមសូត្រ

### អំពីឆ្អឹង

មនុស្សយើងឈរត្រង់ខ្លួនបានដោយសារឆ្អឹងខ្នង ឆ្អឹងដៃជើង ឆ្អឹងសន្លាក់ដៃ ជើង ។ ឆ្អឹងជាប់គ្នាទៅវិញទៅមកទាំងសរសៃតសាច់ ។ ក្បាលមានឆ្អឹងលលាដ៍ ដូចជាប្រអប់មួយមានខួរនៅក្នុងនោះ ។ នៅខាងមុខមានឆ្អឹងមុខ គឺឆ្អឹងប្រមុះឆ្អឹងថ្ពាល់ទាំងឆ្អឹងថ្គាម ។ ដងខ្លួនមានឆ្អឹងទ្រូងឆ្អឹងខ្នង ឆ្អឹងជំនីរ ឆ្អឹងត្រគាក ។ បើអ្នកស្ទាបដងខ្លួនអ្នកមើល អ្នកនឹងឃើញមាន

ធ្នឹមអណ្តាតមួយ គឺធ្នឹមអង្គញ់សំរាប់ទប់ជើងកុំឲ្យភ្លាត់ទៅខាងមុខ ។ ៚

ពាក្យពិបាក ៖– ឈរ - ដោយសារ - សន្ទាក់ - សរសៃ - អង្គញ់ - អណ្តាត ។

## តែងសេចក្តី

ចូរអ្នកអធិប្បាយអំពីសិស្សម្នាក់ខំរៀនសូត្រ ដែលអ្នកបានស្គាល់ជាប្រាកដ ។

សេចក្តីផ្តើម – ឈ្មោះ អាយុ ថ្នាក់ដែលសិស្សនោះរៀន ។

សេចក្តីរាប់រៀប – នៅក្នុងកន្លែងរៀន តើសិស្សនោះប្រព្រឹត្តដូចម្តេចខ្លះ ?– វេលាចេញពីសាលារៀនទៅផ្ទះ ? – ចេញពីផ្ទះដើរតាមផ្លូវទៅសាលារៀន ? ។

សេចក្តីបញ្ចប់ – យោបល់របស់អ្នកយល់ឃើញអំពីសិស្សដែលខំរៀន ។

## អក្សរផ្សំ

ឃ ឈ ឃ ល ស ណ

ឃ ឃា ឃី ឃូ ឃួ ឃឿ ឃៀ ឃៃ ឃេ ឃោ ឃោះ ឃុំ ឃា ។

គេឃុំឃាំងអាឃី អាឃួឈរឃំ កុំឃោរឃោ ។

## បង្រៀនពាក្យ ហាត់ភាសា

### អាទិត្យទី ២.— អំពីសំពត់

នាម — សំពត់អំបោះ ទេសឯក ផាឌិប ស្បៃ អ៊ូ កាម៊្បី សំពត់អន្ទូញ សំពត់ខ្មៅ កំណាត់ផ្កា កំណាត់ឆ្នូត កំណាត់ពណ៌ សំពត់សូត្រ (សំពត់ព្រែ) ព្រែឡាញ់ ព្រែលាត ព្រែឡា ព្រែផ្កា ព្រែឈ្លួន ហូល ផាមួង ល្បើក បរបាប់ ។

គុណនាម — ស្តើង ក្រាស់ ម៉ដ្ឋ គ្រើម គគ្រាត រលីង រលើប ផុយ ដាប់ ទន់ រឹង ក្តឹផ្ទុក ចាំង គាប់ ល្អិល ។

កិរិយាសព្ទ.— ដេរសំពត់ កាត់ស្បៃ ហោកផាឌិប អ៊ុតព្រែលាត ផ្តកសំពត់ ជ្រលក់ព្រែ — សំពត់អំបោះ ដុលហូល ស្រះសំពត់ព្រែ ប៉ាក់កាំមី ។

ហាត់ភាសា .— សំឡីកប្បាសសំរាប់ធ្វើអ្វី? សំពត់អំបោះពណ៌សស្តើង សាច់ម៉ដ្ឋរលើង ហើយជិតល្អ គេហៅថាសំពត់អ្វី? (ទេសឯក) ចុះបើសំពត់នោះសាច់គ្រោសរឹងគគ្រាត ហៅថាសំពត់អ្វីវិញ? (ផាឌិប) ។ កំណាត់អ្វីដែលគេយក មកធ្វើជាមុង? ។ល។ ទៀត ។ល។

ការហាត់មាត់ទទេ .— ១- ចូររកពាក្យដែលជាកិរិយា គួរនឹងនិយាយបានមកដាក់ខាងមុខនាម ដែលមាននៅក្នុងវិធីបង្រៀនពាក្យនេះ ៖

ឧទាហរណ៍: កាត់ស្បៃ ។ល។

២- ចូររកនាមសព្ទដែលគួរនឹងនិយាយបាន មកដាក់ខាងមុខគុណនាមដែលមានក្នុងវិធីបង្រៀនពាក្យ ៖

ឧទាហរណ៍: ស្បៃស្តើង ។ ផាឌិបគ្រាស់ ។ល។

៣ ចូររកពាក្យផ្ទុយនឹងពាក្យទាំងនេះ ៖ គគ្រាត, ជិតល្អ – ស្តើង – ដាច់ – ក្ដី ។ល។

ការហាត់សរសេរ .– ១ – ចូរតែងជាឃ្លានឹងពាក្យនេះ ៖ –

ជ្រលក់ព្រៃផ្កា - កំណាត់ឆ្នូត - ព្រៃឡាញ់ - សំពត់ហូល ។

២ – ចូរបំពេញឃ្លានៅកន្លែងចន្លោះខាងក្រោមនេះ ៖

ស្រីខ្មែរច្រើនយកសំពត់ទេសឯកសមក... (ផ្តក) នឹងទឹកមក្លៀ ធ្វើជា....(សំពត់ខ្មៅ) ។ នៅស្រុកអាយសំពត់ដែលល្អឆើតផងគេ គឺ.... (សំពត់ហូល) ។ សព្វថ្ងៃនេះប្រុសៗអ្នកស្រុកអាយច្រើន យក.....(ព្រៃឈូន) ឬ.-... (ព្រៃលាត) មកធ្វើជាខោអាវ ។ សំពត់អំបោះ.... (ផុយ) ហើយសាប .... (គគ្រើម) មិន.... ( រលីង ) ដូចសំពត់សូត្រទេ ។

## បង្រៀនមើល

ការរវៃអំបោះហើយនឹងត្បាញសំពត់

សៀវភៅវត្ថុស្តាធ្យាយន៍អាទិកដ្ឋានទំព័រ ១៤៩

# សរសេរតាមសូត្រ

## សំលៀកបំពាក់

មនុស្សត្រូវមានសំលៀកបំពាក់ខ្លួន ដើម្បីការពារទឹកកំដៅព្រះអាទិត្យ ឬនឹងរងា និងសត្វខាំ, ហើយនឹងបិទបាំង កេរ្តិ៍ខ្មាសផង ។ តាមទំនៀមខ្មែរយើងគេស្លៀកសំពត់ចងក្បិនទាំងប្រុសទាំងស្រី ។ សំពត់មានច្រើនបែប គឺសំពត់អំបោះនឹងសំពត់សូត្រ សំពត់ខ្លះមានក្បាច់គំនូរល្អណាស់ ។ ខ្មែរប្រុស ៗ ពាក់អាវកត្រង់មានឡេវយ៉ាងញឹក ស្រី ៗ ពាក់អាវបំពង់វែងធ្លាក់ដល់ជង្គង់ ហើយបង់ក្រមា ។ ទាំងប្រុសទាំងស្រីកាត់សក់ជ្រងខ្លី ប៉ុន្តែខ្មែរយើងចាប់យកតំរាប់តាមជនជាតិប្រទេសក្រៅណាស់ មានប្រុសខ្លះស្លៀកខោពាក់អាវតាមបារាំង ចិន យួន ហើយនិយាយថាមិនចង់ស្លៀកសំពត់ទេ ពីព្រោះមិនចេះមួរក្បិន ។

សរសេរពាក្យពិបាក .— សត្វ ព្រះអាទិត្យ កេរ្តិ៍ ជនជាតិ បារាំង មួរក្បិន ទំនៀម អំបោះ ផ្កាភ្ញី ជង្គង់ ។

## បង្រៀនពាក្យនិងភាសា

### អាទិត្យទី ៣.– គ្រឿងជ្រលក់សំពត់

នាម.– *ផ្លែមក្លឿ សម្បកស្វាយព្រៃ សំបកក្ដុំក្ដែង សំបកស្ដួល សំបកព្រហូត ដើមត្រាំ មើមរមៀត ខ្ទឹមខ្ទុរ ខ្ទឹមឃ្មេ ផ្លែដំពូ លុកឃុត ដក់គាំ ស្បែង ល័ក្ខ ត្រាំ ក្បុង មរ ស្លាប់ ។*

គុណនាម.– *ខ្មៅ ខៀវ លឿង ក្រហម បៃតង ស្វាយ ស ពិបាក ឆ្ងាយ ស្រស់ ខ្ចី ក្រមៅ សព្វ ឆ្អក គាប់ចិត្ត ជិត ។*

កិរិយាសព្ទ.– *ជ្រលក់សំពត់ ត្រាំសំបកស្វាយព្រៃ ត្រវីល័ក្ខ ប្រមោកសូត្រ រំលាយក្បុង ប្រចាប់មរ ពូតសំពត់ ហាលស្លាប់ ស្ដោះសំបកស្ដួល គាស់មើមរមៀត ។*

ហាត់ភាសា.– *នាំសិស្សនិយាយ.*

*នឹងជ្រលក់សំពត់អំបោះឬសំពត់សូត្រឲ្យបានពណ៌ខ្មៅ ខ្មែរយើងធ្វើនឹងអ្វី ? បើពណ៌ក្រហមទុំគេធ្វើនឹងអ្វី ? បើជ្រលក់សូត្រឲ្យមានពណ៌*

ល្អស្រស់គេជ្រលក់នឹងអ្វី ? នៅស្រុកយើងគេជ្រលក់សំពត់ឲ្យបានពណ៌ខ្មៅខៀវនឹងអ្វី ? លុកឃុតពណ៌ដូចម្ដេច ?

ប្ដូរតែងជាឃ្លានឹងពាក្យ.— ស្វាយ ប៉ុន្តែឲ្យប្រើសេចក្ដីផ្សេងពីគ្នា ។

ឧទាហរណ៍: ដើមស្វាយនេះមានផ្លែច្រើន ។ សំពត់សូត្រនេះពណ៌ស្វាយ ។ សេះមានសក់មួយកញ្ចុំនៅលើក្បាលហៅថាសក់ស្វាយ ។

ការហាត់សរសេរ.— ប្ដូរតែងជាឃ្លានឹងពាក្យជាអាយតនិបាត "ដើម្បី": "ដើម្បីនឹងជ្រលក់សំពត់អំបោះ គេត្រូវប្របាច់សំពត់នេះក្នុងទឹកជូះ" ប្ដូរតែងពាក្យបីឃ្លាឲ្យដូចគ្នា ប៉ុន្តែឲ្យនិយាយពីរបស់អ្វីផ្សេងវិញ ។

ឧទាហរណ៍: ដើម្បីនឹងបេះផ្លែមក្លឿគេត្រូវកាប់មែកវាទម្លាក់ចុះ ។ល។

ប្ដូរតែងពាក្យបីឃ្លានឹងកិរិយាសព្ទ "ប្រមោក" ប៉ុន្តែឲ្យប្រើសេចក្ដីផ្សេងពីគ្នា

ឧទាហរណ៍: ស្រីនេះចេះប្រមោកសូត្រស្អាតណាស់ ។ កូននេះម្ដាយវាយដូចជាប្រមោក ប៉ុន្តែវាមិនរាងចាលសោះ ។ រឿងនេះគេប្រមោកមកលើយើងហើយ ។

## បង្រៀនមើល

# ការជ្រលក់សំពត់

*សៀវភៅវត្ថុស្វាធ្យាយន៍ អាទិកដ្ឋានទំព័រ១៥២*

កែតម្រូវពាក្យ.– ប្រហ៊ូត = ព្រហូត = ។ លាក់ = ល័ក្ដ ឬ ល័ខ ។ សូត = សូត្រ ។

## សរសេរតាមសូត្រ

# អំពីដើមត្រុំ

ត្រុំជារុក្ខជាតិតូច កំពស់ពីចិតសិបសង់ទីម៉ែត្រ ទៅដល់មួយម៉ែត្រ ដើមវាឯស្និតដុះតំរៀបជាជួរ ផ្កាមានបង្កោមពណ៌ក្រហមនៅខាងក្នុងផ្លែ មានគ្រាប់តូចៗពណ៌ខៀវ ។ គេដាំត្រុំនៅដីខ្សាច់សើមៗ គេព្រោះគ្រាប់ឬគេដាំជាជួរ ចម្ងាយពីគ្នាប្រហែលហុកសិបសង់ទីម៉ែត្រ ឯចំការត្រុំនោះត្រូវគេឲ្យស្អាតហ្មត់ចត់ ហើយឧស្សាហ៍បោចស្មៅចេញផង ៗ ដល់កាលណាត្រុំមានផ្កា គេប្រូតមែកទុកកំពស់ពីព្រះធរណីប្រ-

ហែល២៥សង់ទីម៉ែត្រ ក្រោយនោះបន្តិច គេឃើញមានខ្នងថ្មីដុះឡើងវិញហ័សណាស់ ។ លុះបានប្រាំមួយអាទិត្យ ឬពីរខែ គេច្រូតត្រុំបានម្តងទៀត បើនៅលើធរណីណាដែលល្អ គេច្រូតបានបីដងផង ។ ដំណាំត្រុំគេមិនត្រូវទុកឲ្យនៅក្នុងចំការឲ្យហួសមួយឆ្នាំទេ ។

ពាក្យពិបាក.— រុក្ខជាតិ – ដុះ – ពណ៌ – ហូតបត់ – ឧស្សាហ៍ ធរណី – បង្កោម – កំពស់ – ខ្នង ។

## តែងសេចក្តី

១ – ចូរនិយាយអំពីសំលៀកបំពាក់របស់អ្នកស្រុក ដែលអ្នកបានឃើញហើយ មានខុសគ្នាដូចម្តេចខ្លះ ? អ្នកចូលចិត្តសំលៀកបំពាក់បែបណា ? ពីព្រោះអ្វីបានជាអ្នកចូលចិត្តសំលៀកបំពាក់បែបនោះ ? ។

២ – លោកគ្រូអ្នកបានពន្យល់ថាឲ្យសំអាតខ្លួនប្រាណ – សំលៀកបំពាក់ ផ្ទះសម្បែង - ចំណីអាហារហើយទឹកផឹក ។ ចូរអ្នកអធិប្បាយអំពីសេចក្តីដែលលោកពន្យល់នោះថាដូចម្តេចខ្លះ ? ការសំអាតមានប្រយោជន៍ដូចម្តេចខ្លះ ? ។

គំរូសេចក្ដី ទី២

(សុំឲ្យធ្វើតាមគំរូសេចក្ដី ក្នុងអាទិត្យទី៣ នៃទស្សនាវដ្ដីឆ្នាំទី១ លេខ៦ ទំព័រ ២០) ។

# កុមារដ្ឋាន

## រៀនពាក្យនិងភាសា

### អាទិត្យទី១.— អំពីផ្ទះ

ផ្ទះ, ផ្ទះរោង, ផ្ទះខ្ទម, ផ្ទះតឹក, ផ្ទះតៀម, ផ្ទះថ្ម ផ្ទះឈើ ។ ផ្ទះថ្មី, ទំនើប, ចាស់, មាំ, ដាច់, ទូលាយ, ចង្អៀត, គ្រាំគ្រា ។ សង់ផ្ទះ, រុះរើ, នៅ, ជួសជុល. គួរផែនទី, វាស់ខ្នាត ។

ភាសា.— ឪពុកម្ដាយអ្នកមានទីលំនៅក្នុងផ្ទះអ្វី ? ផ្ទះឪពុកម្ដាយអ្នកជាផ្ទះថ្មីឬចាស់ ? ផ្ទះនោះជាលំនៅទូលាយឬចង្អៀត ? ខ្ពស់ឬទាប ? ផ្ទះរោងនិងផ្ទះខ្ទមមានទ្រង់ទ្រាយដូចគ្នាឬខុសគ្នា ? អ្នកដែលបានឃើញគេសង់ផ្ទះឬទេ ?

## ពាក្យត្រូវរៀនក្នុងកំឡុងអាទិត្យទី១

ខ្ទម, រោង, កុដិ, ព្រះវិហារ, ប្រាសាទ, វាំង (ដំណាក់ស្ដេច) ព្រះពន្លា (រោងឬបារាំបំណាតនៃស្ដេច) សាលា (ផ្ទះដាទីប្រជុំជន ឬផ្ទះសំរាប់សំណាក់), ផ្ទះស្លឹក, ផ្ទះស្បូវ, ផ្ទះក្បឿង, ផ្ទះក្ដារ, ផ្ទះឥដ្ឋ ឬថ្ម ប្រាង្គ មណ្ឌប (អានថាម័នដប់ គឺប្រាសាទតូចៗមានកំពូលដូចមកុដ)ៗ

ខ្ទមតែកតោក, រោងធំល្វឹង, កុដិក្រញឹប, ព្រះវិហារស្រឡះ ស្រអិបខ្ពស់, ទាប, ប្រាសាទឆើតឆាយ, វាំងចាស់, វាំងមាំមួន ៗ

ឈប់សំរាក, ប្រជុំគ្នា, បត, ជ្រក, ប្រថាប់, សង់រោង, សាងព្រះវិហារ, កសាងសាលា, ឡើងផ្ទះ, ចូលរោង, សម្ភោជ ឬសម្ភោទ (ធ្វើ ឬ ឡើងផ្ទះ) ៗ

## អាទិត្យទី ២ – គ្រឿង-តុតាំង

ទូ, តុ, គ្រែ, កៅអី, ជើងមា, ជើងតាំង (តុរៀបគ្រឿងសំអាង)

កញ្ចក់,

ហិប, វ៉ាលីស, ពូក, ខ្នើយ, កន្ទេល, ព្រំ, កំរាល, នាឡិកាយោល, គោម, ក្ដារងឿ, រនាំង, វាំងនន, មុខទ្វារ, មុខគ្រែ, ឡប់ឡៃ, រំកាយ

បង្អួចទ្វារ, ៗ

តួរលោង, គ្រែខ្ពស់, ពូកទន់, កំរាលល្អ, រនាំងក្រហម, ៗ

ខាត់ទូ, ជូតតុ, រៀបគ្រែ, រើគ្រែ, អង្គុយលើកៅអី, ដុះកញ្ចក់, ក្រាលកន្ទេល, ផ្ទៀងម៉ោង, ចាក់នាឡិកា ឬនាលិកា, ដាក់រនាំង, លើករនាំង, បាំងទ្វារ, ថែទាំ, ជូតជុស, សំអាត ៗ

អាទិត្យទី ៣ .- គ្រឿងសង់ផ្ទះ ឈើប្រើការក្នុងគ្រឿងផ្ទះ

សសរ, ជញ្ជាំង, កំរាល, បន្ទប់, ល្វែង, ល្វែងចន្ទ (ល្វែងកណ្ដាល) ល្វែងទទួលភ្ញៀវ, ល្វែងដេក, បន្ទប់គ្រឿងសំអាង, បាំងសាច, ពនហាល, បន្ទប់ទឹក, ផ្ទះបាយ ៗ

ឈើដាប់ = ផ្ចឹក, សុក្រំ, កំងក្នុំ, កកោះ, គ្រញូង, នាងនួន, គគីរ, ពពេល ៗ

ឈើទាល, ត្រាច, ត្បែង, ខ្ទុង, ស្រឡៅ, ខ្វារ, ឫស្សី, ផ្តៅ ៗ

សសរមូល, ត្រង់, វែង, ខ្លី, ជញ្ជាំងទាប, ស្រោង, ស្រអិប កំរាលរលោង, ស្មើ, ដាប់, ផុយ, ឈើដាប់, រឹង, ទន់, ៗ

លើកសសរ, ក្រាលក្ដារ, រនាប, ឥដ្ឋ, ៗ ទទួលភ្ញៀវ, រៀបចំផ្ទះ តាក់តែង, លាបថ្នាំ, ទល់, ជ្រែង ៗ

អាទិត្យទី ៤.– ជាងឈើ, ជាងដែក, ជាងបាយអ, ជាងលាបថ្នាំ ។ ជាងប្រសប់. ឆ្មាត, ស្ទាត់, ហ្មត់ចត់, នឹងធឹង, គំរក់, ល្អ, ខ្ជិល ។ សិតសសារ, ឈូស, ចាំង, ដំរង់, ស្ទង់, ក្ដិត, ផ្គុំ, អារ, កាត់, ដាប់, ចោះ, ទម្លុះ, ខួង, ប្រក់, ព្រំ, លាប, គូរ ។

អាទិត្យទី ១ .– មេរៀនលេខ ១ – អំពីទីលំនៅ-ផ្ទះខ្មែរ

(សុំមើលក្នុងសៀវភៅវិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ ១០៦)

## រៀនមើល – សរសេរ

អាទិត្យទី ២.– ភូមិខ្ញុំ

(សុំមើលសៀវភៅវិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ ១០៨)

អាទិត្យទី ៣.– ផ្សារនៅភូមិខ្ញុំ

(សៀវភៅខេមរភាសាកុមារដ្ឋានទំព័រ ១០៩)

អាទិត្យទី៤ .– ក្រុមជាងសង់ផ្ទះ

(បរិវច្ឆ - ទំព័រ ៣៤)

កិច្ចដែលរៀនមើលសុំគ្រូធ្វើដូចរបៀបខាងក្រោមនេះ ៖

១– សុំបង្រៀនឲ្យចេះមើលប្រាកដ គឺមើលឲ្យច្បាស់ហើយឲ្យត្រូវឃ្លាផង ទើបគេស្ដាប់សេចក្ដីបាន ។

២– សុំឲ្យពន្យល់ពាក្យ ហើយឲ្យសិស្សចេះពន្យល់ពាក្យនោះវិញផង ។

៣– ត្រូវឲ្យសិស្សប្រយ័ត្នគ្រប់គ្នានឹងមើលហើយនឹងពន្យល់ ។

៤– សុំតែងពាក្យសួរតាមសេចក្ដីមើល ឲ្យសិស្សប្រុងឆ្លើយគ្រប់គ្នា ។

---

# បរិច្ឆណាដ្ឋាន

## រៀនពាក្យនិងភាសា

### អាទិត្យទី ១.– ច្បាប់បញ្ញត្តិអំពីកាប់គាស់ព្រៃ

(សុំយកតាមសៀវភៅវត្ថុស្វាធ្យាយន៍អាទិកដ្ឋានទំព័រ ១០៤)

នាម.– ច្បាប់ (បញ្ញត្តិ) ព្រៃរក្សាទុក បណ្ដាពស្ត្រ ព្រៃបំរុងទុក ក្រសួងព្រៃ ភោគសម្បត្តិ ពន្ធ

គុណនាម.– អន្តរាយ វិនាស ហិន ហិនហោច ចំរើន

**កិរិយាស័ព្ទ.–** បញ្ញត្ត កាប់គាស់ រក្សា ថែរក្សា បំរុង ទំនុកបំរុង កាន់កាប់ ដេញ ដេញថ្លៃ ស្ម័គ្រចិត្ត ព្រមព្រៀង ការពារ សំរាំង មាន អំណាច ប្រើប្រាស់ ត្រូវការ បង់ពន្ធ អនុញ្ញាត ។

**ភាសា.–** តាមបញ្ញត្តិច្បាប់ព្រៃឈើចែកជាប៉ុន្មានយ៉ាង ? ហៅថា ព្រៃអ្វីខ្លះ ? ពដការប្រគល់ឲ្យក្រសួងអ្វីឲ្យកាន់កាប់រក្សាព្រៃឈើ ? ប្រយោជន៍អ្វីបានជាគេឲ្យរក្សាព្រៃឈើ ? អ្នកនៅជិតព្រៃរក្សាទុកនោះ ពដការបើកអំណាចឲ្យធ្វើបានដូចម្ដេចខ្លះ ? ឯព្រៃណាដែលបំរុងទុកនោះ ត្រូវបានអំណាចធ្វើបានដូចម្ដេចខ្លះ ? ពដការក្រសួងមេព្រៃបើកអំណាចឲ្យកាប់បានយ៉ាងណា ?

## អាទិត្យទី ២ – បញ្ញត្តិកាប់រានព្រៃ

( សុំយកតាមក្បួនសៀវភៅវត្ថុសាធ្យាយទំព័រ ១០៧ )

**នាម.–** កិច្ចការៈ ចង្កេះភ្នំ ខ្នងភ្នំ ជើងភ្នំ ដើមស្រល់ វល្លិអង្គុត កៅស៊ូ ជ័រ

**គុណនាម.–** រាបស្មើ ( កុំច្រឡំនឹងរៀប រៀបចំ ) រលីង ពោត ( កុំច្រឡំ នឹងពោធ ) ទំនាប ទាប ។

**កិរិយា.–** រានព្រៃ ( កុំច្រឡំនឹងរៀនអក្សរ ) ផ្ដួល ( ដួល ) រំលំ ឃ្លាំល្បាត យាមល្បាត ។

ភាសា ៖- ពីព្រោះអ្វីបានជាមានបញ្ញត្តិថាបើកាប់ឈើក្នុងព្រៃ ត្រូវឲ្យទុកខ្លះ?

មួយទៀតថា បើនឹងកាប់ ត្រូវកាប់ឲ្យរាបស្មើនឹងដី តើពីព្រោះអ្វី? បើទីកន្លែងណាជាដីចោតឬមានថ្មច្រើន តើត្រូវកាប់យ៉ាងណា? ពីព្រោះអ្វី? បើកាប់ឈើនៅភ្នំ តើត្រូវកាប់យ៉ាងណា? ពីព្រោះអ្វី?

អាទិត្យទី ៣.– នេសាទុបករណ៍សំរាប់ព្រានព្រៃ

នាម.– កាំភ្លើង ស្នា ធ្នូ (ធនូ) ព្រួញ អង្គប់ ខ្នារ (អង្គប់មានព្រួញ) ទ្រពង់ស្នា ដៃស្នា ស្នូកកាំភ្លើង ត្រែកាំ-ភ្លើង កៃកាំភ្លើង បន្ទោះស្នា ប្រតឹង លប់ អន្ទាក់ កាំភ្លោះ ។

គុណនាម.– កាំភ្លើងខ្លែង ស្នាធន់ ដៃត្រង់ គ្រាប់រហ័ស ស្នូកកាំភ្លើងវែង ដងខ្នារគោង ។

កិរិយា.– ទាញឈ្នួស ដំរង់ព្រួញ ពត់ព្រួញ ដំឡើងស្នា លោះកៃ ដាក់គ្រាប់ លាបជ័រ លើកសត្វ ដេញទន្សាយ ដាក់ដង់ ចុះខ្វែកក្រោក ។

ភាសា .— ព្រានដែលរកស៊ីទាក់បចាត ហៅដូចម្ដេច ? (ហ្មបចាត) នេសាទុបករណ៍អ្វីខ្លះទៀតដែលអ្នកស្គាល់ ? គេធ្វើដូចម្ដេចនឹងចាប់ទន្សាយបាន ? បណ្ដាពួកនេសាទ នេសាទអ្វីដែលមានប្រយោជន៍ធំ ? (នេសាទត្រី)

## អាទិត្យទី ៤ .— សត្វព្រៃដែលគេបាញ់

នាម.— ដំរី រមាស ប្រើស ព្រាយ ទន្សោង ខ្លា ជ្រូក ឈ្លូស ទន្សាយ ក្ដាន់ រមាំង គោព្រៃ ទុង ត្រដក់ រនាល សាច់ ភ្លុក កុយ ស្នែង ស្បែក ស្លាប ។

គុណនាម.— ធំ ធាត់ សាហាវ ស្គម កាច ស្លូត ថោក ថ្លៃ ។

កិរិយា.— ទាក់ដំរី បាញ់ខ្លា ដេញទន្សាយ លក់ភ្លុកដំរី មិនត្រូវសម្លាប់សត្វ ។

## រៀនមើល សរសេរ

អាទិត្យទី ១.— ច្បាប់បញ្ញត្តិអំពីកាប់គាស់ព្រៃ

(សុំមើលក្នុងសៀវភៅវត្ថុស្តាធ្យាយន៍ ទំព័រ ១០៤)

## អាទិត្យទី២.— បញ្ញត្តិកាប់រានព្រៃ

(សៀវភៅវត្ថុស្វាធ្យាយ៍ទំព័រ ១០៧)

## អាទិត្យទី៣ .— មេរៀន — សត្វព្រៃ

នៅក្នុងព្រៃធំៗមានសត្វជាច្រើន ។ សត្វដែលកាចសាហាវជាងគេ គឺខ្លាវាស៊ីសាច់ឆៅជាអាហារ ។ សត្វដំរីធំជាងគេទាំងអស់ ប៉ុន្តែមិនកាចប៉ុន្មានទេ គេចាប់យកមកប្រើបានដូចគោក្របីដែរ ។

ជ្រូកព្រៃជាសត្វចង្រៃ វាស៊ីដំណាំៈយើង ។ ខ្លាឃ្មុំស៊ីឃ្មុំជាអាហារ ប្រើស ក្តាន់ ឈ្លូស ទន្សាយ ស៊ីស្មៅទាំងអស់ សាច់វាមានរសជាតិណាស់ សំពោចច្រើននៅក្នុងគុម្ពឫស្សីហើយចេញលួចចាប់មាន់ស៊ីវេលាយប់ ។ សុំបង្រៀនសិស្សឲ្យស្គាល់សត្វទាំងអស់នេះ ដូច្នេះត្រូវរកផ្ទាំងគំនូរដែលមានរូបសត្វព្រៃមកបង្ហាញសិស្សឲ្យឃើញផង ពីព្រោះកុមារខ្លះមិនស្គាល់សត្វទាំងនោះទេ ។

## អាទិត្យទី ៤.— សត្វស្លាបព្រៃ

ត្រដក់ធំជាងគេទាំងអស់ ។ វាជាការបានហាមប្រាមមិនឲ្យបាញ់

ទុង រនាល ត្រដក់ទេ ។ ក្រៀលច្រើនយំពេលថ្ងៃត្រង់ ។ នៅក្នុងបឹងមានប្រវិកទឹងទោមច្រើនណាស់ ។ ស្មោញ ក្អែកទឹក រកស៊ីក្នុងបឹងចាប់ត្រីស៊ីជាអាហារ ។ ខ្វែករកស៊ីតែវេលាយប់ជាសត្វស៊ីត្រីដែរ ។ បបាតខ្លួនតូចពណ៌ខៀវស្រងាត់ ។

អកច្រើនតែយំពេលថ្ងៃត្រង់ ។ ខ្លែងជាសត្វចង្រៃវាឆាបកូនមាន់ ។ ទីទុយជាសត្វមានប្រយោជន៍ណាស់ វាចាប់សត្វចង្រៃស៊ីដូចជាក្ដាមជាដើមដែលវាកាត់ស្រូវយើង ។

មានមនុស្សច្រើនចូលចិត្តបរិភោគសាច់មាន់ទោ ។ ពពូលពណ៌ខៀវវាស៊ីផ្លែពោធិ៍និងផ្លែជ្រៃ ។ លលករកស៊ីដោយវាលស្រែ ។

---

## មជ្ឈិមដ្ឋានទី ២ និង ឧត្តមដ្ឋាន

### នព្វន្ត

អាទិត្យទី ១ . – អំពីចំនួនបែងភាគ (ត) ។

១ – លេខបូកចំនួនបែងភាគមានភាគបែងដូចគ្នា ។

ឧទាហរណ៍: $\frac{៥}{១២} + \frac{៧}{១២} + \frac{៣}{១២} = \frac{៥+៧+៣}{១២} = \frac{១៥}{១២}$ ឬ $១\frac{៣}{១២}$

វិធាន: ដើម្បីនឹងបូកចំនួនបែងភាគដែលមានភាគបែងត្រូវគ្នានោះ គេត្រូវបូកភាគយកនឹងភាគយក ឯភាគបែងនៅដដែល ។

បើចំនួនបែងភាគមានភាគបែងខុសគ្នាទេនោះ គប្បីដម្រូវភាគបែងឲ្យត្រូវគ្នាសិន ទើបបូកដូចខាងលើនេះ ។

២ – លេខបូកចំនួនគត់នឹងភាគ ។

វិធាន: ដើម្បីបូកចំនួនគត់នឹងភាគ នោះត្រូវបូកចំនួនគត់នឹងចំនួនគត់ ចំនួនបែងភាគនឹងចំនួនបែងភាគ រួចយកចំនួនសរុបផ្គុំគ្នា ។

ឧទាហរណ៍: $២\frac{៣}{៤} + ៥\frac{៨}{៧} + ៦\frac{៥}{១២} =$

$$២ + ៥ + ៦ + \frac{៣}{៤} + \frac{៧}{៨} + \frac{៥}{១២} = ១៣ + ២\frac{១}{២៤} = ១៥\frac{១}{២៤}$$

ការហាត់.– ចូរធ្វើលេខខាងក្រោមនេះ ៖

$\frac{២}{៣} + \frac{៣}{៤}$ ។ $\frac{១}{៤} + \frac{៣}{៨} + \frac{៥}{១៦}$ ។ $\frac{២}{៣}\ \frac{១}{៩} + \frac{៤}{២៧}$

$៩\frac{១}{៦} + ៧\frac{១}{៦}$ ។ $៥\frac{៣}{៧} + ១១\frac{៤}{៧}$ ។ $៥\frac{៧}{១២}\ ១០\frac{៣}{៤}$ ។

ចំណោទ . – មេឃុំម្នាក់ទារពន្ធបានសុទ្ធតែប្រាក់កាក់ ០,១០ បានយកទៅដាក់ឃុំម្ដង $\frac{៧}{១២}$ ម្ដងទៀត $\frac{៩}{៣៦}$ ឯប្រាក់ដែលនៅសល់

ពុំទាន់ដាក់ឃ្លាំងនោះទម្ងន់ ៤០៥ ក្រាម តើប្រាក់ពន្ធទាំងអស់ប៉ុន្មានរៀល ?

( តាក់ ០រ,១០មួយ ទម្ងន់ ២ ក្រ, ៧ ) ។

## អាទិត្យទី ២.– លេខសងចំនួនបែងភាគ ។

វិធានទី១.– ដើម្បីធ្វើលេខហូតដែលមានភាគបែងត្រូវគ្នា គេសងតែភាគយកនឹងភាគយក ឯភាគបែងគង់នៅដូចដើម ។

ឧទាហរណ៍ : $\frac{៧}{១៣} - \frac{៤}{១៣} = \frac{៧-៤}{១៣} - \frac{៣}{១៣}$

វិធានទី២.– នឹងធ្វើលេខសងដែលមានភាគបែងមិនត្រូវគ្នា នោះគេដម្រូវភាគបែងឲ្យត្រូវគ្នាសិន រួចហូតតែភាគយកនឹងភាគយក ទុកភាគបែងនៅដដែល ។

ឧទាហរណ៍ : $\frac{៧}{៨} - \frac{៣}{៥} = \frac{៣៥}{៤០} - \frac{២៤}{៤០} = \frac{៣៥ - ២៤}{៤០} = \frac{១១}{៤០}$

វិធានទី៣.– នឹងធ្វើលេខសងចំនួនគត់នឹងភាគ មានភាគបែងមិនត្រូវគ្នា នោះគេដម្រូវភាគបែងឲ្យត្រូវគ្នា រួចគេហូតចំនួនគត់នឹងចំនួនគត់ ចំនួនបែងភាគនឹងបែងភាគ បើលេខបែងភាគខាងឆ្វេងតូចជាងចំនួនបែងភាគខាងស្តាំ ត្រូវដកចំនួនរាយមួយពីចំនួនគត់មកបន្ថែមលើចំនួនបែងភាគដែលតូចនោះ

ឧទាហរណ៍ : $៩\frac{១}{៦} - ២\frac{១១}{១៥} = ៩\frac{៥}{៣០} - ២\frac{២២}{៣០}$

គេយក $\frac{២២}{៣០}$ ទៅហូតនឹង $\frac{៥}{៣០}$ មិនបានទេ ព្រោះ $\frac{៥}{៣០}$ តូចជាង $\frac{២២}{៣០}$ ត្រូវយកកាយ ១ ពី ៩ មកថែមលើចំនួន $\frac{៥}{៣០}$

គឺ $៩\frac{៥}{៣០} - ២\frac{២២}{៣០} = ៨ + \frac{៣០}{៣០} + \frac{៥}{៣០} - ២\frac{២២}{៣០} = ៨\frac{៣៥}{៣០} - ២\frac{២២}{៣០} = (៨ - ២) - \frac{៣៥ - ២២}{៣០} = ៦\frac{១៣}{៣០}$

ការហាត់ .– ចូរធ្វើលេខខាងក្រោមនេះ ៖

$\frac{៧}{៨} - \frac{៣}{៨}$ ។ $\frac{៣}{៤} - \frac{៥}{១២}$ ។ $\frac{៥}{៦} - \frac{១}{៨}$ ។ $៨\frac{៥}{៦} - ៣\frac{១}{៤}$ $១៣\frac{១១}{១២} - ៩\frac{៥}{១២}$ ។ $៤\frac{១៤}{១៥} - ១\frac{៣}{៥}$ ។

បំណោទ .– កម្មករម្នាក់ត្រូវជីកប្រឡាយមួយប្រវែង ២៣ម $\frac{១}{៦}$ កម្មករនោះជីកប្រឡាយបានប្រវែង ១៧ម $\frac{៧}{១២}$ ហើយ តើប្រឡាយពុំទាន់ជីកនៅចម្ងាយប៉ុន្មានទៀត ?

អាទិត្យទី៣ .– ការហាត់គិតទំប្រាជ្ញ ។ គុណចំនួនទនឹង ១,៥ គេត្រូវយកពាក់កណ្ដាលចំនួនទៅថែមលើចំនួននោះវិញ ។

ឧទាហរណ៍: ៤ + ១,៥ = ៤ + ២ = ៦

គុណចំនួនទនឹង ២,៥ គេគុណចំនួននោះនឹង ១០ រួច បែកនឹង ៤ ។

ឧទាហរណ៍: ៤ × ២,៥ = (៤ × ១០) : ៤ = ១០ ដើម្បីចែកចំ-នួននឹង ២,៥ គេចែកចំនួននោះនឹង ១០ រួចគុណនឹង ៤ ។

ឧទាហរណ៍: ៤ : ២,៥ = (៤ : ១០) × ៤ = ១,៦

អាទិត្យទី ៤. – រៀនសាឡើងវិញ ។

## រង្វាស់រង្វាល់

អំពីរង្វាស់សម្រាប់វាស់ឧស ។ នៅគ្រប់ស្រុកគេវាស់ឈើសម្រាប់សង់ផ្ទះឬឧសដុត នឹងម៉ែត្រគូប ។

មា៉ត្រដែលគេហៅថា ម៉ែត្រគូបឧស (ម៣ឧ)

១ម៉ែត្រគូបឧស = ១ម៉ែត្រគូប ។

រង្វាស់ដែលមានរួបនោះគឺ : ម៉ែត្រគូបឧស ។ ទ្វេម៉ែត្រគូបឧសនឹង ៥ ម៉ែត្រគូបឧស ។

រង្វាស់ដែលធំជាងគឺ ដេកាម៉ែត្រគូបឧស = ១០ម៉ែត្រគូប រង្វាស់ដែលតូចនោះគឺ ដេស៊ីម៉ែត្រគូបឧស = ០ម៣,១ ។

សរសេរទឹងមើលចំនួន .— ទឹងមើលឬទឹងសរសេរ ចំនួនជាម៉ែត្រគុបឧស គេសរសេរដេកាម៉ែត្រឧសនៅខាងឆ្វេង ដេស៊ីម៉ែត្រគុបឧសនៅខាងស្តាំម៉ែត្រគុបឧស ។

ឧទាហរណ៍: ៥ ដេកាម៉ែត្រគុបឧស ៣ ម៉ែត្រគុបឧស ២ ដេស៊ី-ម៉ែត្រគុបឧស ត្រូវសរសេរដូចខាងក្រោមនេះ ៖

៥៣ $^{ម៣}$,២ ឬ ៥ដាម $^{៣}$,៣២ ។

ការហាត់ .— ដើម្បីនឹងធ្វើបុសសសរសង់ផ្ទះ គេបានបោះបុស ៤៦ កំណាត់ទៅក្នុងដី បុសនីមួយៗបួនជ្រុងស្មើ ទំហំ ៨ សម. មួយជ្រុង ហើយប្រវែង ០ $^{ម}$៧៥ តើឈើដែលប្រើធ្វើបុសនោះថ្លៃប៉ុន្មាន បើគេដឹងថាឈើ ១ ម៉ែត្រគុបថ្លៃ ៥២០ រៀល ? ។

## ធរណីមាណសាស្ត្រ

អាទិត្យទី ១ .— អំពីដុំបួនជ្រុងស្មើ - ដុំបួនជ្រុងស្មើ គឺជាដុំវត្ថុរឹងមួយ មានមុខ៦ពង៤ជ្រុងស្មើៗគ្នា មុខនីមួយៗទុកជាបាតរបស់ដុំ ៤ ជ្រុងស្មើ ហើយមានទ្រនុង ១២ ស្មើៗគ្នា ។




១– រកផ្ទៃក្រៅ. – នឹងរកផ្ទៃក្រៅដុំបួនជ្រុងស្មើ ត្រូវយកផ្ទៃមុខមួយគុណនឹង៤ ។

ផ្ទៃក្រ = ទ្រនុង × ទ្រនុង × ៤ =

២ – រកផ្ទៃរួម .– នឹងរកផ្ទៃរួមត្រូវយកផ្ទៃបាតគុណនឹង ៦ ។

ផ្ទៃរួម= ទ្រនុង × ទ្រនុង × ៦ =

៣– រកចំនួនទំហំ .– នឹងរកចំនួនទំហំត្រូវយកជ្រុង គុណជា ៣ លើក ។ ហ = ជ្រ × ជ្រ × ជ្រ

ការហាត់ .– ចូរធ្វើដុំបួនជ្រុងស្មើមួយនឹងក្រដាសក្រាស់ទំហំ ១ ដ.ម.មួយជ្រុង ។

អាទិត្យទី ២._ អំពីដុំ៤ជ្រុងទ្រវែង .– ឈើហ៊ប់ ដុំឥដ្ឋ ប្រអប់ឈើគូស ។ល។ ជាដុំបួនជ្រុងទ្រវែង ។ ដុំបួនជ្រុងទ្រវែង ជាវត្ថុមានមុខបួនជ្រុងទ្រវែង ៦ ស្មើគ្នាមួយគូ ៗ ហើយមានទ្រនុង១២ ។ ដុំបួនជ្រុងទ្រវែង មានប្រវែង៣យ៉ាងខុសគ្នា គឺ ទោល បន្ទា នឹងប្រវែង ឬ ទទឹងកំពស់នឹងបណ្តោយ ។

ឧទាហរណ៍: ឥដ្ឋ១ដុំ ទទឹង ១០ សម, កំពស់ ៤ សម, បណ្ដោយ ២០សម. នោះ ចំនួនទំហំឥដ្ឋនោះមាន ១០ សម, × ៤ × ២០ ។

វិធាន: នឹងរកចំនួនទំហំដុំបួនជ្រុងទ្រវែង ត្រូវយកទទឹងគុណនឹងកំពស់គុណនឹងបណ្ដោយ

ហ = ទ × ក × ប

ការហាត់ .– ឲ្យសិស្សធ្វើដុំបួនជ្រុងទ្រវែងនឹងក្រដាសក្រាស់ ៗ

---

# វាធិកដ្ឋាន

## នព្វន្ត

### អាទិត្យទី ១ .– ១ – ចំនួនបែងភាគគត់

ការដែលមានប្រយោជន៍បំផុតនោះ ត្រូវឲ្យសិស្សធ្វើកិច្ចជាមួយផង ឲ្យបានឃើញជាក់ស្ដែងនឹងភ្នែក ។ ហេតុនេះក្នុងសិស្សម្នាក់ ១ ត្រូវឲ្យមានក្រដាសពីរសន្លឹក ដើម្បីនឹងផ្ដើមហេតុរៀនវិធីបែងភាគគត់នេះ ឲ្យសិស្សបានដឹងជាក់ច្បាស់ ។ យើងយកក្រដាសមួយសន្លឹកបត់ជា ៨ ចំណែកឲ្យស្មើគ្នា មួយចំណែក ១ ហៅថាភាគ ៨ ពីក្រដាសមួយ

សន្លឹកគត់ ៗ ប្ដូរកាត់តាមផ្ចិតឲ្យខុសបែបឲ្យខុសចំនួនចំណែកពីមុន តែឲ្យស្មើគ្នាជានិច្ច រួចយកចំណែកមួយ ឬ ចំណែកទាំងនោះមកហៅ ហើយប្រាប់ឈ្មោះតាមដែលបែងភាគ ៗ សិស្សម្នាក់ៗ ត្រូវឲ្យមានបន្ទាត់សំប៉ែតមួយ ធ្វើនឹងក្រដាសយ៉ាងក្រាស់ ឬបន្ទះដែលមានបណ្ដោយមួយដេស៊ីម៉ែត្រ ៗ នេះជាម៉ែត្រមួយ (បត់បាន) ៗ ម៉ែត្រនេះក្រិតជាប៉ុន្មានចំណែក ? ចំណែកទាំងនោះស្មើគ្នាឬទេ ? បើដូច្នេះគឺជាមួយភាគដប់នៃម៉ែត្រ ដែលគេហៅថាដេស៊ីម៉ែត្រ ៗ ដេស៊ីម៉ែត្រគឺមួយភាគដប់តូចជាងម៉ែត្រ ៗ មួយម៉ែត្រមានដប់ដេស៊ីម៉ែត្រ ៗ (គេសរសេរកាត់ ដ. ម.) ៗ ឧបមាដូចជា ២ ម = ២០ ដម . ៣៤ = ៣៤០ ដម. ៥០ ដ, ម = ៥ ម . ៗ

វិធីហាត់គិតមាត់ទទេ .— យើងគូរឬគូសបន្ទាត់មួយដេស៊ីម៉ែត្រមួយ ហើយយើងញែកម្រាមដៃមួយប្រាប់បណ្ដោយដេស៊ីម៉ែត្រ ៗ យើងវាស់បណ្ដោយសៀវភៅមើល សៀវភៅសរសេរ ៗ យើងទាយស្មានទទឹងតុ កំពស់ជើងម៉ា កំពស់ជញ្ជាំង ៗល ៗ យើងត្រួតត្រាផ្ទៀងវាស់ឲ្យជាក់ច្បាស់នឹងដេស៊ីម៉ែត្រ ៗ មានប៉ុន្មានដេស៊ីម៉ែត្រក្នុង ៣ ម. ? ៥ ម? ២ ម ? នឹងកន្លះ ? ៤ ម . នឹងកន្លះ ? ខ្សែនេះមានបណ្ដោយ ១ ម.

នៅសល់ប៉ុន្មានបើខ្ញុំកាត់ ២ ដម ? ៤ ដម. ? ដើម្បីឲ្យបានបន្ទាត់មួយបណ្ដោយ ១ ម. គេត្រូវថែមប៉ុន្មានដេស៊ីម៉ែត្រទៀតទៅនឹង ៧ ដម. ទៅនឹង ៤ ដម. ? ទៅនឹង ២ ដម. ? ។ល។

វិធីហាត់សរសេរ — ចូរធ្វើលេខដូចមានខាងក្រោមនេះ៖

៣០ ដម. + ២០ ដម = . . . ដ.ម ឬ . . . ម ។ ២ ម ៥ ដ.ម + ១ ម ៣ ដ.ម = . . . ។ ៤ ម ៣ ដ.ម − ៣ ម ២ ដម = . . . ។ ១០ ម ៧ ដម − ៧ ម ៩ ដម = . . . ដម ។ ៣៥ ដម × ២ . . . ។

បំណោទ.— ខ្ញុំមានខ្សែស្ទូចបីកំណាត់ ពីរកំណាត់មានបណ្ដោយ ៩ ដេស៊ីម៉ែត្រ ក្នុង ១ កំណាត់ មួយកំណាត់ទៀតមានបណ្ដោយ ៧ ដេស៊ីម៉ែត្រ ។

តើខ្សែស្ទូចទាំងអស់មានបណ្ដោយប្រវែងប៉ុន្មាន ? ។ល។

## ២ — អំពីបែងភាគដប់ពីមួយគត់

យើងវាស់បណ្ដោយត្រូវយើងឃើញ ២ ម នឹង ៤ដ.ម ឬ ២ ម ៤ ក្នុងភាគដប់ ពីមួយម៉ែត្រគត់ ។ យើងសរសេរ ២ ម ៤ ។ យើងវាស់បណ្ដោយវត្ថុមួយទៀត យើងឃើញ ៧ ដេស៊ីម៉ែត្រ ឬ ៧ ក្នុងភាគដប់

ពីមួយម៉ែត្រគត់យើងសរសេរ ០ម,៧ ៗ

មេរៀនឲ្យចាំស្ទាត់ .– នៅក្នុងលេខបែងភាគគត់ លេខទី ១នៅខាងស្ដាំ កណ្ដកសញ្ញា គឺចំនួនភាគដប់ពីមួយគត់ ៗ យើងមើលចំនួនបែងភាគគត់ ២៤,៣ យើងថា ២៤ គត់ ក្នុងភាគដប់ពីមួយគត់ ៗ ០,៥ យើងថាប្រាំក្នុងភាគដប់ពីមួយគត់ ៗ

វិធីហាត់សរសេរ •– ចូរសរសេរជាលេខបែងភាគគត់ ដូចមានលេខនៅខាងក្រោមនេះ ៗ បួនក្នុងភាគដប់ពីមួយគត់ ៗ ពីដណ្ដប់ពាយប្ដុគត់ ៗ បើក្នុងភាគដប់ ពីមួយគត់ ៗ ប្រាំមួយពាយប្ដុគត់ ៗ ប្រាំបីក្នុងភាគដប់ពីមួយគត់ ៗ ប្រាំបួនក្នុងភាគដប់ ពីមួយគត់ ៗល ៗ

បំណោទ .– ខ្ញុំមានខ្សែពីកន្ទុយ ខ្សែមួយមានប្រវែង ៤ម៣ ខ្សែ ១ ទៀត ២ម៥ ខ្ញុំចងខ្សែនេះតគ្នា ៗ សួរថា បណ្ដោយខ្សែទាំងពីរប៉ុន្មាន ? បើខ្ញុំធ្វើតណអស់ ០ម១ ៗ មានឈើពីរដើម ដើមទី១មានប្រវែង៦ម២ ដើមទីពីរមានប្រវែងលើសដើមទី១, ១ម៤ ៗ តើដើមឈើទីពីរមានប្រវែងប៉ុន្មានម៉ែត្រ ? ឈើទាំងពីរដើមមានប្រវែងទាំងអស់ប៉ុន្មាន ?

អាទិត្យទី២.– ១ បែងភាគរយពីមួយគត់ ៗ ២ – បែងភាគ

ពាន់ពីមួយបេគគត់ សូមធ្វើដូចអាទិត្យមុន ហើយបំបែកវិធីហាត់គិតមាត់ទទេ នឹងហាត់សរសេរដូចមានរបៀបក្នុងអាទិត្យទី ១ គ្រប់សព្វស្រាប់ ។

អាទិត្យទី ៣ .— លេខបូកមានត្រាទុក ។ ២ កិរិយាបូកលេខបែងភាគគត់

អាទិត្យទី៤ .— ១– លេខសងមានត្រាទុក ។ លេខសងចំនួនបែងភាគគត់

## រង្វាស់រង្វាល់

អាទិត្យទី១ .— ដេស៊ីលីត្រ ដេស៊ីក្រាម

រង្វាល់ចំណុះជាប្រធានមានចំនួនគត់គឺអ្វី ? រង្វាល់លីត្រនេះយើងវាល់ស្រាទំពាំងបាយជូរមួយដបបានឬទេ ? ដបទឹកក្រូចមួយដបបានឬទេ ? ហេតុអ្វីបានជាវាល់មិនបាន ? ដើម្បីនឹងវាស់ប្រវែងខ្លីៗ ជាងម៉ែត្រនោះគេប្រើអ្វី ?

ឯរង្វាល់ចំណុះបើនឹងវាល់វត្ថុអ្វីដែលតូចជាងលីត្រ នោះគេប្រើដេស៊ី-លីត្រដូចដេស៊ីម៉ែត្រដែរ ។ គេសរសេរកាត់ៈ ដ.ល ។ ដេស៊ីលីត្រ

គឺមួយភាគដប់តូចជាងលីត្រ ហេតុដូច្នេះ មួយលីត្រមានដប់ដេស៊ីលីត្រ (១០ដ.ល) ។ សូមគ្រូគ្រាផ្ទៀងមើលទឹងលីត្រហើយទឹងដេស៊ីលីត្រ ។ វាល់ទឹងដេស៊ីលីត្រ ហើយចាក់ទៅក្នុងលីត្រ ។ របៀបបង្រៀនដេស៊ីក្រាមក៏ដូចដេស៊ីលីត្រដែរ ។

វិធីហាត់គិតមាត់ទទេ.– មានប៉ុន្មានដេស៊ីលីត្រក្នុង ២លីត្រ ? ៥ លីត្រ ? ៣លីត្រ ? ១ លីត្រកន្លះ ? ៣ លីត្រកន្លះ ? ដបមួយមានស្រាមួយលីត្រ គេបានលក់អស់៥ ដ.ល នៅសល់ស្រាប៉ុន្មានដេស៊ីលីត្រទៀត ? ។

វិធីហាត់សរសេរ.– ចូរធ្វើលេខខាងក្រោមនេះ ៖

២៤ក + ៤ក = ដ.ក ។ ២១ក២ + ១៣ក៣ = ។ ៧ក + ៣ក៦ = ។ ១៤ល២ – ៦ល២ = ។ ២៨ល៩ – ៩ល៦ = ។ ៥ក៦ × ៧ក២ = ។ ៦ល៧ × ០ល៦ = ។ ៩ល៥ : ៥ = ។ ១៦ល៤ : ៤ = ។

បំណោទ.– ជាងទងម្នាក់លាយមាសធ្វើខ្សែដៃមួយទម្ងន់១២ក-៨ ដល់ធ្វើហើយទៅខ្សែដៃនោះនៅទម្ងន់តែ ៨ក៥ ។ ទម្ងន់មាសប៉ុន្មាន

ដែលជាងនោះកោសខាតចេញ ? ។ ខែដែលមាសនោះថ្លៃប៉ុន្មាន ? បើជាងនោះលក់ក្នុង១ក្រាម ថ្លៃ ៩ រៀល ? ។

២– ធុទិនមួយមានស្រា៥ល៨ គេដួសស្រានោះមុនដំបូង ២ ល រួច ១ ល៦ ហើយគេចាក់ចូលទៅវិញ១ល៩ តើធុទិននោះនៅមានស្រាប៉ុន្មានលីត្រទៀត ? ។

អាទិត្យទី២.– សង្ទីលីត្រ សង្ទីក្រាម

សូមធ្វើដូចអាទិត្យទី ១ ហើយបំបែកវិធីហាត់គិតមាត់ទទេនិងហាត់សរសេរឲ្យបានច្រើន ។

អាទិត្យទី៣. មីលីលីត្រ មីលីក្រាម

---

# បច្ឆិមដ្ឋានទី ១

[illegible] ១

អាទិត្យទី១.– ១-លេខសង់បែងភាគ -២- លេខធំខាងលើជាលេខដុំ លេខតូចខាងក្រោមមានបែងភាគ ។

សូមមើលរបៀបដូចអាទិកដ្ឋាន ។

## ហាត់សរសេរ.– បំណោទ

១ – មេការម្នាក់ឲ្យប្រាក់ទៅជាង៣នាក់ចំនួន៧០០៛ ជាងទី១បាន ២៥៧៛,៧៥ ជាងទី២បាន ៣៩៛,៥០ តិចជាងទី១ ហើយនឹងជាងទី ៣ ចំនួនប្រាក់ដែលនៅសល់ ។ តើជាងម្នាក់ៗត្រូវបានចំណែកប៉ុន្មានរៀល ? ។ – ២ –អ្នកចំការម្នាក់ធ្វើបរក្នុងមួយត្រីមាសបាន១៥៨២៛,៩០ ហើយរកបរផ្សេងៗក្នុងមួយឆ្នាំបាន ១៩២៦៛,៥០ ។ អ្នកនោះបង់ពន្ធក្នុងមួយឆ្នាំអស់ ៣៨៥៛,៧៥ តើអ្នកចំការនោះនៅសល់ប្រាក់ប៉ុន្មានក្នុងមួយឆ្នាំ ? ។

## អាទិត្យទី ២.– ១- លេខបែក (លេខហារមានលេខពីរខ្ទង់)

សូមមើលរបៀបដូចអាទិកដ្ឋាន ។

២.– អំពីម៉ោង មិនុត សិកុន ។ល។

ឆ្នាំ.– ក្នុងមួយឆ្នាំមាន ១២ ខែ ឬ ៣៦៥ ថ្ងៃ ឯ ៣៦៦ ថ្ងៃ នោះមាន៤ឆ្នាំម្ដង ។

ថ្ងៃ.– មួយថ្ងៃមាន ២៤ ម៉ោង

ម៉ោង.– មួយម៉ោងមាន ៦០ មិនុត ឬ នាទី

មិនុត.– មួយមិនុតមាន ៦០ សិកុន

ខែ .– មួយខែមាន ៣០ ឬ ៣១ ថ្ងៃ លើកតែខែហ្វេវ្រិយេមាន ២៨ ឬ ២៩ ថ្ងៃ ( ឯ ២៩ នោះបួនឆ្នាំមានម្តង )

ហាត់គិតមាត់ទទេ .– ក្នុងកន្លះថ្ងៃមានប៉ុន្មានម៉ោង ? មានប៉ុន្មានមីនុតក្នុងកន្លះម៉ោង ? មួយម៉ោង ? ពីរម៉ោងកន្លះ ? ត្រូវបន្ថែមប៉ុន្មានទៅ ២៥ មីនុត ទើបបានកន្លះម៉ោង ? ទៅ ៤០ មីនុតទើបបានមួយម៉ោង ? ។

## អាទិត្យ ទី ៣ .– អំពីលេខបូក ម៉ោង · មីនុត

ឧបមា : $៣^{ម},៤០^{ន} + ៥^{ម},១៥^{ន} =$

គេបាន : $៤០^{ន} + ១៥^{ន} = ៥៥$ នាទី $៣^{ម} + ៥ម = ៨$ម៉ោង

ឬ $៣,^{ម}៤០^{ន} + ៥,^{ម}១៥^{ន} = ៨,^{ម}៥៥$ .

មេរៀន .– នឹងធ្វើលេខបូករកចំនួនពេលម៉ោង គេត្រូវបូកឲ្យដាច់ពីគ្នា គឺ មីនុតជាមួយមីនុត ម៉ោងជាមួយនឹងម៉ោង រួចគេរួមចំនួនទាំងអស់ បើកាលណាចំនួនសិកុងលើសមួយមីនុត ចំនួនមីនុតលើសមួយម៉ោង គេត្រូវហូតចំនួនមីនុតពីចំនួនសិកុង ចំនួនម៉ោងពីចំនួនមីនុត មុននឹងបូកសរុបទាំងអស់ ។

ឧបមា $= ២,^{ម}២៩,^{ន}៤៣^{ស} + ៥,^{ម}៥០,^{ន}២៦^{ស} =$

$៤៣^{ស} + ២៦^{ស} = ៦៩^{ស}$ ឬ $១,^{ន}៩^{ស}$

$២៩^{ន} + ៥០^{ន} = ៧៩^{ន}$ ឬ $១,^{ម}១៩^{ន}$

$២^{ម} + ៥^{ម} =$ ៧ម៉ោង

ដូច្នេះ : $២.^{ម}២៩.^{ន}៤៣^{ស} + ៥.^{ម}៥០.^{ន}២៦^{ស} = ៧^{ម} + ១,^{ម}១៩^{ន} + ១,^{ន}៩^{ស} = ៨,^{ម}២០.^{ន}៩.^{ស}$

ហាត់ធ្វើនៅក្ដារខៀន ·– $២,^{ម}១៥^{ន} + ៣^{ម}៣២^{ន}$ ; $៥.^{ម}៣៥ + ៣.^{ម}៤០^{ន}$ ; $២.^{ម}៤៧^{ន} + ១.^{ម}២៥$ ; $៥.^{ម}៣៧ + ៦.^{ម}៣៨^{ន}$ ;

ហាត់សរសេរ·– បំណោទ

១.– ស្រីដេរអាវម្នាក់ ដេរនៅថ្ងៃច័ន្ទ $៤,^{ម}២០^{ន}$ ថ្ងៃអង្គារបាន $៦,^{ម}១៥^{ន}$. ថ្ងៃពុធបាន $៧,^{ម}២៥.^{ន}$ តើស្រីនោះដេរបានប៉ុន្មានម៉ោង ហើយបានឈ្នួលប៉ុន្មាន បើគិតមួយម៉ោងគេឲ្យ $១,^{រ}៥០$? ។

២.– រថភ្លើងមួយបើកចេញទៅបាន $៨៤^{គ}.^{ម}២៥$ ក្នុង $២.^{ម}២៥$ ហើយបើកទៅទៀតបាន $៦៥,^{គ}.^{ម}៥$ ក្នុង $១,^{ម}៤៨.^{ន}$ តើរថភ្លើងនោះបើកទៅបានចម្ងាយប៉ុន្មានគីឡូម៉ែត្រ ? ប៉ុន្មានម៉ោងទាំងអស់ ?

## រង្វាស់រង្វាល់

អំពីសង្ទីម៉ែត្រ - សង្ទីលីត្រ - សង្ទីក្រាម - មីលីម៉ែត្រ - មីលីក្រាម ។ សូមមើលរបៀបបង្រៀនថ្នាក់ អាទិកដ្ឋាន ។

---

# មធ្យមដ្ឋានទី១

## ធរណី[illegible]ណាសាស្ត្រ

អាទិត្យទី១នឹងទី២ .— ត្រីកោណ ៖ កំពូលបាត, បន្ទាត់បែងមុម បន្ទាត់ អឌ្ឍបាតកំពស់ ។




អត្ថន័យ — ១ — ត្រីកោណ គឺជាផ្ទៃមួយមានជ្រុង៣ នឹងមុម ៣ ។

២ — ចំណុចដែលជ្រុង២ប្រសព្វគ្នា ហៅថាកំពូលត្រីកោណ គឺចំណុច ក, ខ, គ ។ ដូច្នេះត្រីកោណមានកំពូលប៉ុន្មាន ?

៣ — ជ្រុងត្រីកោណដែលនៅឈមមុខនឹងកំពូលនិមួយ ៗ ហៅថា

បាតត្រីកោណ ៗ ដូច្នេះត្រីកោណមានបាតប៉ុន្មាន ?




៤- បន្ទាត់បែងមុម

ការគូរបន្ទាត់បែងមុម - ក). គំរិតប្រវែងស្មើគ្នា លើជ្រុងមុមទាំងពីរ ដោយគិតពីកំពូល ខ មក ៗ ខ) យកប្រដាប់ឈានពីចំណុច ង និង ឃ តាមរង្វះតែមួយ ៗ បំណែកមណ្ឌល ប្រសព្វគ្នាត្រង់ចំណុច ប ៗ គ) គូសភ្ជាប់កំពូល ខនឹងចំណុចប ៗ បន្ទាត់ ខ-ប នេះបែងមុម ក.ខ.គ. ជាពីរចំណែកស្មើគ្នា ៗ បន្ទាត់នេះ ហៅថាបន្ទាត់បែងមុម ៗ




៥ – បន្ទាត់អឌ្ឍបាត គឺបន្ទាត់ដែលកើតឡើងដោយភ្ជាប់កំពូលនិមួយ ៗ ទៅនឹងចំណុចពាក់កណ្ដាលបាតដែលនៅឈមមុខកំពូលនោះ ៗ ក្នុងត្រីកោណមានបន្ទាត់អឌ្ឍបាតប៉ុន្មាន ?




៦– កំពស់ - គឺបន្ទាត់ដែលចេញពីកំពូលធ្លាក់សំយុងត្រង់ទៅលើបាត ។ ក្នុងត្រីកោណមានកំពស់ប៉ុន្មាន ? សុំគ្រូបញ្ជាក់សិស្សឲ្យស្គាល់បន្ទាត់ទាំង ៣ មុខនេះឲ្យមែនទែនព្រមទាំងឲ្យចេះគូរដោយត្រឹមត្រូវផង ។ ឯកំពស់មិនមែនសំរេចនៅតែក្នុងផ្ទៃត្រីកោណទាំងអស់ឡើយ ជួនកាលនៅក្រៅផ្ទៃក៏មានដូចគំនូរខាងក្រោមនេះ ៖




## អាទិត្យទី ៣ និងទី ៤ .– រាងត្រីកោណផ្សេងៗ

**របៀបបង្រៀន .–** សុំគ្រូរករបស់មានរាងជាត្រីកោណផ្សេងៗ ឬគូរត្រីកោណផ្សេងៗ នៅក្តារខៀន ឲ្យសិស្សមើលពិនិត្យរក លក្ខណៈប្លែកផ្សេងៗ ។




១– ត្រីកោណមានជ្រុងទាំង ៣ ស្មើគ្នា ៖

ជ្រុង ក ខ = . ខ គ = . គ ក .

មុម ទាំង ៣ ប៉ុនគ្នា ៖   មុម ក.ខ.គ = ខគក




២– ត្រីកោណមានជ្រុង២ ស្មើគ្នា ៖

ជ្រុង កខ = ខគ -




៣– ត្រីកោណមានមុមកែងមួយ ៖

មុម ខកគ ជាមុមកែង.




៤– ត្រីកោណមានជ្រុងទាំង៣ពុំ ស្មើគ្នា ។

# បរិច្ឆណភជ្ជាន

## ឥព្វដ្ឋ

## មេរៀនទី ១.– អំពីចំនួនទសភាគ

• ក្នុងវិធីបង្រៀនរង្វាស់រង្វាល់ពីខែមកកាសិស្សបានរៀនអំពីរង្វាស់រង្វាល់ដែលតូចជាងរង្វាស់-រង្វាល់ ជាប្រធានដូចជាដេស៊ីម៉ែត្រសង់ទីម៉ែត្រ. មីលីម៉ែត្រ ។ល។ វិជ្ជានេះនាំឲ្យងាយបង្រៀនចំនួនទសភាគ ។

៦ ការបង្រៀនចំនួនទសភាគនេះត្រូវឲ្យសិស្សស្គាល់កណ្ដក់សញ្ញា ចំនួនដុំនឹងចំនួនភាគដប់ ភាគរយ ភាគពាន់ ។

## របៀបបង្រៀន :—

១– គ្រូជាចំនួនទសភាគ ១ ដូចជា២៍ ៥៧ ។ ៣ម៉ឺ ៤៦ ។

២– គ្រូសរសេរចំនួននេះនៅលើក្ដារខៀនហើយពន្យល់ ចំនួនដុំ កណ្ដក់សញ្ញា ចំនួនទសភាគ ហើយពន្យល់របៀបមើលនឹងរបៀបសរសេរចំនួនទសភាគ ។

៣– ការហាត់បញ្ជាក់នៅលើក្ដារខៀន ។

គ្រូឲ្យសិស្សរកចំនួនទសភាគ – ឲ្យសរសេរចំនួននោះនៅលើក្ដារខៀន

៤– ការហាត់បញ្ជាក់នៅលើក្ដារឆ្នួន ។

គ្រូជាចំនួនទសភាគឲ្យសិស្សសរសេរនៅលើក្ដារឆ្នួន ។

៥– ការហាត់បញ្ជាក់នៅក្នុងសៀវភៅ–

ចូរសរសេរចំនួនខាងក្រោមនេះជាចំនួនទសភាគ ៖

២៧៥សេន= ។ ៣០៧ សល = ។ ១៥២០សម= ។

៥៦៣មក្រ= ។ ២១០ សេន= ។ ៣៥៩ សម = ។

## មេរៀនទី២.– ចំនួនទសភាគ-លេខបូកនិងលេខសង ។

មេរៀនទី៣ .— ចំនួនទសភាគ - លេខគុណនឹងមេ៩ ។

មេរៀនទី៤ .— ចំនួនទសភាគ .- លេខចែកនឹងមេ៩ ។

មេរៀនទី៥ .— សាបញ្ជាក់អំពីមេលេខគុណទាំងអស់ ។

សូមមើលតាមរបៀបដែលរៀបចំបង្រៀនអំពីខែមុនៗ ហើយសូមតែងការហាត់ឲ្យសព្វគ្រប់ផង ។

## រង្វាស់រង្វាល់

ក្នុងខែនេះត្រូវបង្រៀនអំពីរង្វាស់ - រង្វាល់ - កូនទម្ងន់ដែលមានជាប្រាកដសម្រាប់ប្រើប្រាស់ ។

មេរៀនទី១ .— អំពីរង្វាស់ដែលមានប្រាកដ:

| | | |
|---|---|---|
| ដេកាម៉ែត្រក្រោះ | ដេកាម៉ែត្រ | កន្ទះដេកាម៉ែត្រ |
| ម៉ែត្រក្រោះ | ម៉ែត្រ | កន្ទះម៉ែត្រ |
| ដេស៊ីម៉ែត្រក្រោះ | ដេស៊ីម៉ែត្រ | |

ការបំណាំ .— រង្វាស់គីឡូម៉ែត្រ - ហិកតូម៉ែត្រ - សង់ទីម៉ែត្រ មីលីម៉ែត្រ មានតែឈ្មោះសំរាប់ហៅ សំរាប់គិតគន់នព្វន្ត បើត្រូវការវាស់ គេប្រើរង្វាស់ដេកាម៉ែត្រ - ម៉ែត្រនឹងដេស៊ីម៉ែត្រ ។

មេរៀនទី២ .– អំពីរង្វាស់ដែលមានជាប្រាកដ -

ហិកតូលីត្រ កន្ទះហិកតូលីត្រ

ដេកាលីត្រភ្លោះ ដេកាលីត្រ កន្ទះដេកាលីត្រ

លីត្រភ្លោះ លីត្រ កន្ទះលីត្រ

ដេស៊ីលីត្រភ្លោះ ដេស៊ីលីត្រ កន្ទះដេស៊ីលីត្រ

សង្ទីលីត្រភ្លោះ សង្ទីលីត្រ

ការបំណាំ .– តាំងពីរង្វាល់ ហិកតូលីត្រ ដល់សង្ទីលីត្រ គេសង្កេតឃើញភ្លោះហើយនឹងកន្ទះឬពាក់កណ្ដាល ។

មេរៀនទី ៣.– អំពីកូនទម្ងន់ដែលមានជាប្រាកដ ។

ក - កូនទម្ងន់ធ្វើអំពីសំណប៉ាហាំង :

៥០ គីឡូក្រាម – ២០ គ.ក្រ – ១០ គ.ក្រ – ៥.គក្រ ២ គ.ក្រ
១ គ.ក្រ – ៥ ហ.ក្រ – ២ហ.ក្រ – ១ហ.ក្រ – ៥ដា.ក្រ ។

ខ– កូនទម្ងន់ធ្វើអំពីស្ពាន់ :

៥ គក្រ – ២គក្រ – ១គក្រ – ៥ហក្រ – ២ហក្រ – ១ហក្រ
៥ ដាក្រ – ២ដាក្រ – ១ដាក្រ – ៥ក្រ – ២ក្រ – ១ក្រាម

គ — កូនទម្ងន់ធ្វើអំពីបន្ទះស្ពាន់ឬនិកល :

៥ ដក្រ   ២ ដក្រ   ១ ដក្រ

៥ សក្រ   ២ សក្រ   ១ សក្រ

៥ មក្រ   ២ មក្រ   ១ មក្រ

ការបំណាំ.— តាំងពីកូនទម្ងន់ ៥០គ.ក្ររហូតដល់កូនទម្ងន់ ១ ស.ក្រ គេពិនិត្យឃើញគ្រោះនឹងកន្ទុះប្តាក់កណ្តាល ។

មេរៀនទី ៤.— សាបស្រៀនពីដើមឡើងវិញ ។

សូមតែងការហាត់ឲ្យសព្វគ្រប់ផងតាមរបៀបដែលតែងពីខមុនៗមក ។

---

# កុមារដ្ឋាន

## នព្វន្ត

ចំនួនពី ៧០ ដល់ ៨០

រាប់ពី ១ ដល់ ៨០ — រាប់រាយមួយម្តងៗ ម្តងដប់ៗ លេខបូកនឹងលេខសង មានត្រាទុក កុំឲ្យលេខសរុបហួសពី ៨០ លេខគុណនឹង ២ ចែកវត្ថុផ្សេងៗជាពីរផ្នែកស្មើគ្នា ។

មតិសិក្សា ៈ– គ្រូឲ្យសិស្សរាប់ពី ១ ដល់ ៧០ បន្ទុមម្តង ២ ម្តង ៣ ម្តង ៤ ៗ រាប់ច្រាស់ពី ៧០ មក ១ បន្ទយម្តង ២ ម្តង ៣ ម្តង ៤ ៗ

មេរៀន .– ចំនួនពី ៧០ ដល់ ៨០

របៀបបង្រៀន .– បង្រៀនរាប់មើលចំនួន សរសេរចំនួន ត្រូវសរសេរលេខពី ១ ដល់ ៧០ នឹងដីសនៅក្តារខៀន ៗ

អំពីការរៀបចំជាមុន .– ត្រូវមានរបស់ដល់ចំនួន ៨០

១–បង្រៀនរាប់ .– ត្រូវមានរបស់ដូចជាចង្កើះចងជាបាច់ដប់ៗ បាន ៨ បាច់ ឬ លុយសេនចងជាចង្កោមដប់ ៗ បាន ៨ ចង្កោម ៗ

ក) - រាប់ម្តងដប់ ៗ .– ឲ្យសិស្សរាប់ចង្កើះ ១ បាច់ៗ ឬ លុយសេន ១ ចង្កោម ១ ៗ រាប់នឹងថា ១ បាច់ ឬ ១ ចង្កោមមាន ១០ ៗ ឲ្យរាប់ថា ១០-២០-៣០-៤០-៥០-៦០-៧០

ខ) - រាប់ម្តងមួយ ៗ .– សូមឲ្យប្រាប់សិស្សថា យើង មាន៧០ ហើយ ៗ ឥឡូវនេះយើងស្រាយបាច់ ឬ ចង្កោមទី

៨ ទៀត ហើយយើងបន្ថែមមួយម្ដង ៗ ទៅលើចំនួន៧០ ៗ យើងថា ៧០ នឹង ១ ត្រូវជា ៧១ ៗ ៧០ នឹង ២ ត្រូវជា ៧២ ៗ ៧០ នឹង ៥ ត្រូវជា ៧៥ ៗ (ផ្សំបានលេខណាមួយ ៗ ហើយ សូមគ្រូសរសេរលេខនោះ នៅលើក្ដារខៀនតពីលេខ ៧០ ៗ សូមសរសេរលេខរៀនថ្មីនឹងដីសពណ៌ ) ៗ រហូតដល់ ៧០ នឹង ១០ ត្រូវជា៨០ យើងសរសេរលេខ

| | |
|---|---|
| ៨ | ០ |

ដូច្នេះ ៗ សូមពន្យល់ខ្ទង់ ១០ នឹង ខ្ទង់រាយថាមានលេខ ៨ នៅខ្ទង់ដប់ លេខសូន្យនៅខ្ទង់រាយ ៗ សូមឲ្យសិស្សសរសេរលេខ ៨០ គ្រប់គ្នានៅក្ដារឆ្នួនរៀងខ្លួន ៗ សូមឲ្យសិស្សរាប់បន្ថែម ពីរ ៗ បី ៗ បួន ៗ ពី ១ ដល់ ៨០ ហើយរាប់បន្ថយមកវិញ ៗ

២–បង្រៀនមើលចំនួន .– សូមឲ្យសិស្សមើលលេខពី ៧១ ដល់ ៨០ ថាឲ្យច្បាស់ ៗ ៗ

៣– បង្រៀនសរសេរចំនួន .– សូមឲ្យសិស្សសរសេរលេខពី ៧១ ដល់ ៨០ នៅក្ដារឆ្នួនតាមពាក្យគ្រូថាៈ ដូចជា ៧៣-៧១-៧៥-៧២-៧៨-៨០-៧៤ ៗ លេខបូកនឹងលេខសងដែលមានពីរខ្ទង់ហើយត្រាទុក (លេខសរុបមិនហួសពី ៨០ ) (សរុបបង្រៀនដូចខាងមុន ) ៗ

លេខគុណនឹង ២.- ខ្ញុំគូសបង្កើះ ១ ពីរដង ។ បង្កើះមួយ ២ ដងត្រូវជាបង្កើះ ២ ។

ខ្ញុំរាប់ទៅឃើញបង្កើះមួយ ២ ដង

ខ្ញុំថាៈមួយ ២ ដង ឬ មួយគុណនឹង ២ ត្រូវជា ២ ។

ខ្ញុំសរសេរ ១ × ២ = ២ នេះសញ្ញាលេខគុណ ×

ខ្ញុំគូសបង្កើះពី ១ ដល់ ១០ – ២ ដង ។

| | | | | |
|---|---|---|---|---|
| ខ្ញុំថា មួយ | ២ | ដង | ត្រូវជា | ២ |
| ពីរ | ២ | " | " | ៤ |
| បី | ២ | " | " | ៦ |
| បួន | ២ | " | " | ៨ |
| ប្រាំ | ២ | " | " | ១០ |
| ប្រាំមួយ | ២ | " | " | ១២ |
| ប្រាំពីរ | ២ | " | " | ១៤ |
| ប្រាំបី | ២ | " | " | ១៦ |
| ប្រាំបួន | ២ | " | " | ១៨ |
| ដប់ | ២ | " | " | ២០ |

។..– ល.....។

វិធីហាត់មាត់ទទេ ទឹងសារសោ

ម្រាមដៃ ៥ ពីរដង = .....

គុ ៨ ពីរដង = .....

កៅអី ៩ ពីរដង = ....,

៧ × ២ = : ១០ × ២ = : ៥ × ២ =

៤ × ២ = : ៣ × ២ = : ៩ × ២ =

ចែកវត្ថុ ជាពីរចំណែកស្មើគ្នា

ខ្ញុំគូសចង្កឹះ ៦ ....... ||||||

ខ្ញុំចែកចង្កឹះនេះជា ២ ចំណែកខ្ញុំឃើញ |||·|||

( ក្នុង ១ ចំណែកៗ មានចង្កឹះ ៣ ស្មើគ្នា )

ខ្ញុំថា = ៦ : ២ ត្រូវជា = ៣

ខ្ញុំសារសោ = ៦ : ២ = ៣

នេះសញ្ញាលេខចែក = :

គ្រូដាក់ចង្កឹះ ៣០ នៅលើតុ ហើយហៅសិស្ស ២ នាក់ឲ្យមក យកចង្កឹះម្តងៗ មួយព្រមៗ គ្នា លុះត្រាតែអស់ចង្កឹះពីលើតុ ។

រួចឲ្យសិស្សម្នាក់ៗ រាប់ចង្កឹះចំណែករៀងខ្លួន ។ ឃើញថា ម្នាក់បានចង្កឹះ ១៥ ។

ប្រាប់សិស្សថា: ៣០ ចែកនឹង ២ ត្រូវជា ១៥ ។

សូមបំបែកវិធីហាត់ឲ្យបានច្រើន ដើម្បីឲ្យសិស្សបានយល់ជាក់ច្បាស់ ។

វិធីហាត់មាត់ទទេនឹងហាត់សរសេរ

១៦ : ២ = ; ១៨ : ២ =

១៤ : ២ = ; ១០ : ២ =

៦ : ២ = ; ២ : ២ =

៤០ : ២ = ; ៣០ : ២ =

## រង្វាស់រង្វាល់

### ជញ្ជីង

( សូមរកឬ គូរ ជញ្ជីងគ្រប់បែបឲ្យសិស្សស្គាល់ជញ្ជីងថ្លឹងមាស ជញ្ជីងថាស ជញ្ជីង ខ្សែ ជញ្ជីងប៉ុង )

សូមប្រាប់សិស្សឲ្យដឹង ពីផលប្រយោជន៍នៃជញ្ជីងគ្រប់បែប។ នោះ ទឹងមុខ១ គ្រឿងដែលគេថ្លឹងរបស់ធ្ងន់គេប្រើជញ្ជីងធំ ៗ របស់ស្រាលឬមានដម្លៃគេប្រើជញ្ជីងតូច ៗ ។

សូមយកជញ្ជីងថាសទឹងកូនជញ្ជីងគ្រប់មុខទឹងវត្ថុផ្សេង ៗ ដូចជា ដីស ខ្មៅដៃ – ជនបាកកា សៀវភៅ – មកថ្លឹងឲ្យសិស្សមើល ទឹង បង្រៀនសិស្សឲ្យចេះថ្លឹង ៗ

សូមពន្យល់សិស្សឲ្យដឹងថា លុះត្រាតែជញ្ជីងថាសជញ្ជីងទាំងសង ខាងស្មើគ្នា ហើយម្ជុលកណ្ដាលចង្អុលត្រង់ទៅលើឲ្យត្រង់ស្មោះ ទើបថាថ្លឹងនោះត្រឹមត្រូវ ទម្ងន់នោះស្មើគ្នា ៗ

(ក្នុងខែនេះសូមបង្រៀនឲ្យសិស្សចេះថ្លឹងតែប៉ុណ្ណោះទេ)

---

## មជ្ឈិមដ្ឋាន ទី ២

### វិទ្យាសាស្ត្រ

អាទិត្យ ទី១.- អំពីត្រី ៗ ២- អំពីមណ្ឌុកជាតិ ៗ

សូមមើលហើយបង្រៀនតាមសៀវភៅវិទ្យាសាស្ត្រភាសាបារាំងថ្នាក់ មជ្ឈិមដ្ឋានទីពីរនិងឧត្ដមដ្ឋាន តាំងពីទំព័រទី ១១២ ដល់ទំព័រទី ១៥

អាទិត្យទី២.- ១ –អំពីបាណកជាតិ ៗ ២ – អំពីគណ្ឋិកសត្វ ៗ

សូមបង្រៀនតាមសៀវភៅវត្ថុស្វាធ្យាយន៍ថ្នាក់អាទិកដ្ឋានតាំងពីទំព័រទី ៣២ រហូតដល់ទំព័រទី ៣៤ ។

អាទិត្យទី ៣ – ១ – អំពីឧរង្គសត្វ ។ ២ – អំពីអដ្ឋិប្មសត្វ ។

មើលសៀវភៅដដែលទំព័រ ៣៥ និង ៣៦ ។.

មេរៀនជាគំរូ .– អំពីឧរង្គសត្វ ។

ការពិនិត្យមើលនិងព្យាករ .– យកផ្ទាំងគំនូរ មានរូបសត្វលូនសត្វវារ ដូចជាពស់ អណ្តើក ក្រពើ ។ល។ មកបង្ហាញសិស្ស ហើយនាំសិស្សពិនិត្យមើលរូបរាងសត្វទាំងនោះ ឲ្យបានស្គាល់ច្បាស់ផង ។

លក្ខណៈនៃឧរង្គសត្វ .– ឧរង្គសត្វ គឺជាសត្វលូនដូចជាពស់អន្ទង់ ។ល។ ឬវារដូចជាតុកកែ អណ្តើកជាដើម ។ ខ្លួនវាគ្មានរោមឬស្លាបទេ មានតែស្រកាពាសពេញជុំវិញខ្លួន ឯស្រកាសត្វនេះមិនមែនដូចជាស្រកាត្រីទេ មានស្រកាជាហេតុ ៗ ទេ ។ យើងពិនិត្យមើលខ្លួនជីងចក់ ពីព្រោះសត្វនេះមានច្រើនណាស់នៅប្រទេសយើង ហើយមានឧរង្គសត្វច្រើនទៀតដែលមានភាពដូចសត្វជីងចក់នេះ ។ ស្បែកវាគគ្រាតមានសណ្ឋានដូចជាស្រកាតូច ៗ ពាសពេញទាំងខ្លួន ។

**ឧរង្គសត្វផ្លាស់ទីកន្លែងដោយវារឬលូន.—** ដីងចក់ អណ្ដើក ក្រពើ ។ល។ មានអវយវបួន ដុះចេញពីសងខាងខ្លួន តែវាមិនអាចនឹងដើរបានដូចជាគោក្របីទេ កាលណាវាដើរ វាវារបង្អូសពោះលើដី ។ ពស់អន្ទង់គ្មានជើងទេ ពស់មានច្រើនណាស់នៅប្រទេសយើង ពស់ខ្លះមានពិសដូចជាពស់វែកដំបូក — វែកក្របី ។ល។ ពស់ខ្លះទៀតគ្មានពិសទេ ដូចជាពស់ព្រលិតពស់សម្លាប់អង្កែប ។ល។ ពស់មានពិសសាហាវណាស់ កាលណាវាចឹកសត្វឬមនុស្ស ពិសនោះបណ្ដាលឲ្យដល់ស្លាប់បាន ។

ពស់ទាំងនេះបើវានឹងផ្លាស់ទីកន្លែង វាលូនលើដីតាមចន្លោះដើមស្មៅ ដោយអង្កាញ់ខ្លួនក្ងិកក្ងក់ ។

**ធាតុនៃឧរង្គសត្វ.—** ឧរង្គសត្វជាសត្វមានឈាមត្រជាក់ យើងស្ទាបមើលខ្លួនដីងចក់ យើងដឹងថាត្រជាក់ វាដកដង្ហើមក្ដី ការឈាមរត់ក្នុងខ្លួនវាក្ដី ហាក់ដូចពិបាកណាស់ ដូច្នេះកាលមានចំហាយព្រះអាទិត្យ វាទៅសន្ធឹងខ្លួនហាលកំដៅថ្ងៃ កាលណាត្រជាក់ វាទៅពួននៅក្នុងរន្ធ ឬនៅដោយគៀនគោះ កំបាំងអាកាសត្រជាក់នោះ ។

អាហារនៃឧរង្គសត្វ – ឧរង្គសត្វជាមំសាហារសត្វ ជីង-ចក់ អណ្ដើក ស៊ីសត្វល្អិតជាអាហារ ។ ពស់ស៊ីបក្សីនិងថនិកសត្វតូចៗជាអាហារ ក្រពើជាសត្វសាហាវ វាស៊ីត្រីនិងបក្សីជាដើម ជួនកាលវាចាប់ដល់មនុស្សស៊ីជាអាហារផង ។ ឧរង្គសត្វបង្កើតកូនដោយពងដូចជាបក្សីដែរ ។

សារពើឧរង្គសត្វ.– ឧរង្គសត្វដែលមាននៅក្នុងប្រទេសយើង គឺ ជីងចក់ ថ្លែន តុកកែ ជាស បង្កួយ កន្ហែន ត្រកួត អន្សង អណ្ដើក ពស់ ស៊ីសត្វល្អិតជាអាហារ ហៅថា បាណកាហារ

អណ្ដើកមានឆ្អឹងថ្គាមដូចជាចំពុះ តែឥតធ្មេញទេ ថ្គាមនេះរឹងហើយមុតណាស់ ។ ខ្លួនវានៅក្នុងស្នូក មានតែប្រហោងសំរាប់បញ្ចេញបញ្ចូលក្បាលអវយវៈនិងកន្ទុយ ។ នៅប្រទេសកម្ពុជា មានអណ្ដើកបីយ៉ាង គឺ អណ្ដើកព្រេច នៅលើគោកក្នុងព្រៃភ្នំ អណ្ដើកទឹកសាប នៅក្នុងបឹង ឬក្នុងព្រែក ស្ទឹងទន្លេ អណ្ដើកសមុទ្រនៅក្នុងសមុទ្រ ។ អណ្ដើកសមុទ្រ មានប្រយោជន៍ណាស់ គេយកស្នូកនឹងស្រកាវាធ្វើជាក្រាស់សិតសក់ ជងវ៉ែនតា ប្រអប់បារី ផ្ទិត ។ ល ។ ក្រពើមានរូបរាងដូចជាជីងចក់មួយយ៉ាងធំដែរ ខ្លួនវាមានស្រកាធំដូចជាឆ្អឹងរុំព័ទ្ធជុំវិញខ្លួន ម្រាមជើងវាជាប់

គ្មានស្បែកស្ដើងដូចជាជើងអណ្ដើកដែរ ក្បាលវាធំវែងមានធ្មេញច្រើន កន្ទុយវាធំវែងហើយមាំណាស់ផង ។

មេរៀនសង្ខេប.– ឧរង្គសត្វមានស្បែករុំព័ទ្ធជុំវិញខ្លួន នៅលើស្បែកមានក្រឡាធំឬតូចតាមភាពសត្វធំ–តូច ដូចជាស្រកា វាលូនឬវារ សត្វនេះមានឈាមត្រជាក់ ។ ជីងចក់មានអវយវបួនដុះចេញទៅសងខាងខ្លួន តែខ្លីណាស់ ។ ឧរង្គសត្វ ដែលសភាពដូចជីងចក់គឺ តុកកែ ជាស ថ្លែន បង្កួយ ត្រគួត អន្សង ។ល។ សត្វពស់មានពិសដូចជាពស់វែកដំបូក–វែកស្រវ៉ៃ ។ល។ ពស់ឥតពិស គឺ: ពស់ព្រលិត សម្លាប់កង្កែប ។ល។ វាគ្មានជើងទេ សត្វទាំងនេះ មាននៅប្រទេសយើងច្រើនណាស់ ។ មានពស់ខ្លះទៀតរឹបរិតអាហារស៊ី ដូចជាពស់ថ្លាន់ ។ អណ្ដើកមានបីយ៉ាង គឺ: អណ្ដើកព្រេច អណ្ដើកបឹងនឹងអណ្ដើកសមុទ្រ ។ អណ្ដើកមានថ្គាមជាឆ្អឹងរឹងហើយមុតណាស់ផង មានស្នូកព័ទ្ធជុំវិញខ្លួន ។ ក្រពើសាហាវណាស់ មានស្បែកជាក្រឡារឹងដូចឆ្អឹង វានៅក្នុងបឹងឬស្ទឹង នៅរដូវក្ដៅវាច្រើនឡើងនៅលើគោក តាមមាត់បឹងឬស្ទឹង ដើម្បីទឹងយកចំហាយព្រះអាទិត្យ ។

ពាក្យសួរក្នុងមេរៀន. – សូមតែងពាក្យសួរផងចុះ ។

អាទិត្យទី៤. – សាបស្រៀនមេរៀនក្នុងខែនេះឡើងវិញ ។

## វិធីបង្ការរោគ

មេរៀនក្នុងខែ. – អំពី បុរា ។ ២-រោគកើតមកពីសេពសុរា ។

សូមមើលហើយបង្រៀនតាមសៀវភៅវិធីបង្ការរោគ ត្រង់ទំព័រទី ៥២-៥៣ ។

មេរៀនជាគំរូ. – អំពីរោគបណ្ដាលមកពីៈសេពសុរា ។

សេពសុរានាំឲ្យអាយុខ្លី. – សុរាជាគ្រឿងពុល គួរឲ្យខ្លាច ហើយចៀសវាងកុំផឹកឲ្យសោះ សុរាមិនមែនជាថ្នាំកែរោគ ដូចជាអ្នកប្រមឹកស្មាននោះទេ ទោះជាផឹកបន្ទិចបន្តួចក៏វាធ្វើទុក្ខដល់ក្រពះបាយយើងដែរ ជួនកាលគេយកស្រាទៅផ្សំថ្នាំកែរោគខ្លះដែរ ប៉ុន្តែគេត្រូវការប្រើតិចណាស់ ។ ចូរអ្នកសេព បុរាបន្ទិចមើល ! តើវាដូចម្ដេច ? វាក្ដៅក្រហាយមាត់អណ្ដាត ។ អ្នកដែលឃើញរូបរាងមនុស្សផឹកស្រាជោគជាំឬទេ ? តើមនុស្សនោះដូចម្ដេច ? សុរានាំឲ្យវង្វេងស្មារតី ឲ្យអន់ថយកម្លាំង

រកស៊ីធ្វើការអ្វីមិនកើត បើនឹងនិយាយក៏មិនដឹងខុសត្រូវផង ។ មនុស្សផឹកស្រាជោកជាំពល់ថ្ងៃទៅ តើបណ្ដាលហេតុយ៉ាងណាខ្លះ ក្នុងខ្លួន ? (សូមយកផ្ទាំងគំនូរ មានរូបក្រពះបាយ, សួត, ថ្លើម . . . មនុស្សផឹកស្រាមកបង្ហាញសិស្សឲ្យឃើញច្បាស់ផង) ។ ពិសសុរាបណ្ដាលឲ្យខូចក្រពះបាយ ហើយរលាកក្លាយទៅជាដំបៅនៅក្នុងក្រពះនោះដោយបំហាយក្ដៅនៃសុរា ដំបៅនេះអាចឲ្យអាហាររលាយបានដោយលំបាកណាស់ យូរទៅបណ្ដាលឲ្យកើតរោគផ្សេងៗ នាំឲ្យអាយុខ្លីៗ ជាតិសុរាជ្រាបចូលទៅក្នុងឈាមៗចូលទៅក្នុងបេះដូង បង្កើតឲ្យមានខ្លាញ់ច្រើន ខ្លាញ់នេះឲ្យបេះដូងដើរញាំប់ ហើយមិនស្មើផង ។ សរសៃឈាមរត់ទាំងឡាយក៏ទៅជាក្រិនរឹង នាំឲ្យឈាមរត់ខ្សោយបន្តិចម្ដងៗ ថ្លើមទៀតក៏មានខ្លាញ់ជុះរុំព័ទ្ធ បណ្ដាលឲ្យស្ងួតសោះហើយរឹង ។

ទោសនៃសុរា — សុរាជាគ្រឿងបំពុលច្រើនយ៉ាងណាស់ មនុស្សណាសេពសុរាឲ្យជោកជាំហៅថា << សុរាបានកៈ >> មនុស្សនេះបណ្ដាលឲ្យមានគ្រោះថ្នាក់ដល់វង្សត្រកូលយ៉ាងធំគឺ :

ក - វង្វេងស្មារតី ចេញវាចាព្រហើនឥតមានគោរពញាតញាតិអ្វីឡើយ

ជួនកាលជេរបញ្ចោរ វាយដំប្រពន្ធកូន នាំឲ្យហិនហោចទ្រព្យសម្បត្តិ បើជាអ្នកមានទ្រព្យក៏ត្រឡប់ទៅជាអ្នកក្រវិញបាន ។

ខ— នាំឲ្យថយកម្លាំងរកស៊ីធ្វើការមិនបាន ហើយនិយាយយកខុសជាត្រូវច្រើនពោលពាក្យអសុរោះ ហើយវាសដៃជើងនាំឲ្យអ្នកទាំងពួងធុញទ្រាន់នឹងអាការឫករបស់ខ្លួន ។

គ— សុរាបានកៈជាមនុស្សអកតញ្ញូ (អៈកាត់-ទ្រិក) ពាក្យ (សំ) qui veut dire: ne rendre pas de service). កាលណាមានកូនៗនោះរមែងតែក្រេះ ល្ងីល្ងើធ្កួតជ្រូក ។ល។

ដូចនេះចូរអ្នកកុំសេពសុរាឲ្យសោះ សុរានេះថ្វីជាអាហារដែលអ្នកបរិភោគឲ្យមានកម្លាំងទៅទៀត ហើយនាំឲ្យជោកទាបក្ដេរឈ្លោះជាប់ផុតៗ

មេរៀនសង្ខេប .— សុរាជាគ្រឿងពុល កាលណាសេពសុរាវាបណ្ដាលឲ្យវង្វេងស្មារតី ឲ្យរួយដៃជើងធ្វើការអ្វីពុំបាន នាំឲ្យខ្ជិលច្រអូស ហើយច្រើនតែពោលពាក្យអសុរោះទៅលើប្រពន្ធកូន ជួនកាលជេរវាយឥតញញើតអ្វីឡើយ ។

សុរាបានកៈបណ្ដាលឲ្យខូចខ្លួនគ្រប់ជំពូក ហើយខាតបង់ទ្រព្យរបស់ផង មិនតែប៉ុណ្ណោះវាបណ្ដាលឲ្យកើតរោគផ្សេងៗជាច្រើនដល់ស្លាប់ខ្លួន ។

ដូច្នេះចូរអ្នកកុំសេពសុរាឲ្យសោះ សុរាថ្លៃជាងអាហារទៅទៀត ហើយនាំឲ្យថោកទាបកេរ្តិ៍ឈ្មោះខ្លួនឯង ។.

ពាក្យសួរក្នុងមេរៀន .– សូមតែងពាក្យសួរផងចុះ ។

---

# ឧត្តមដ្ឋាន

## វិទ្យាសាស្ត្រ

មេរៀនក្នុងខែ .– ១- អំពីសណ្ឋានទ្រង់ទ្រាយដី ។ ២- អំពីសិលាជាតិ ។ ៣- អំពីលោហធាតុ ។ ៤ អំពីសារពើលោហធាតុ ។

សូមមើលហើយបង្រៀនតាមសៀវភៅវិទ្យាសាស្ត្រភាសាបារាំង ថ្នាក់មធ្យមដ្ឋាននិងឧត្តមដ្ឋានតាំងពីទំព័រ ២១៤ រហូតដល់ទំព័រ ២២៥។

មេរៀនជាគំរូ .– – អំពីសណ្ឋានទ្រង់ទ្រាយព្រះធរណី ។

ប្រដាប់សម្រាប់បង្រៀន .– យកកែវទឹកមួយយ៉ាងធំ ដាក់ដីខ្សាច់ ដីល្បាប់ ដុំក្រួស រួចចាក់ទឹកដាក់ទៅក្នុងកែវនោះ ហើយកូរវត្ថុទាំងអស់នេះឲ្យលាយឡំគ្នា ទាំងអស់ទុកឲ្យរង ។ យើងឃើញថាដុំក្រួសធ្លាក់ទៅបាតកែវ ពីព្រោះវាធ្ងន់ជាងគេ នៅខាងលើដុំក្រួសគឺដីខ្សាច់

រួចដីល្បប់នៅខាងលើបំផុត ពីព្រោះដីល្បប់ស្រាលជាងក្រួស-ដីខ្សាច់ ៗ ហេតុអ្វីបានជាដីល្បប់ស្រាលជាងគេ ? ពីព្រោះមានលាយកំទេចឈើ. . .ៗ

សណ្ឋានទ្រង់ទ្រាយផែនដី.— ផែនដីរាងមូលដូចផ្លែក្រូចពោធិ៍ សាត់ហើយសំប៉ែតបន្តិចនៅផ្ចិតដីសងខាង ៗ ព្រះធរណីមានជាតិគ្រប់យ៉ាង នៅស្រទាប់លើបំផុត ដែលគេភ្ជួររាស់ហើយដាំដំណាំគ្រប់ដំពូកសម្រាប់ជាអាហារ ឬ ជាសិប្បិយការមនុស្សយើង ស្រទាប់នេះមានលាយសិលាគ្រប់មុខ ដែលលំអិតដោយអំណាចទឹកនឹងខ្យល់អាកាស ៗ ដីណាមានធាតុប្មគ្រប់គ្រាន់ ដីនោះទ្រទ្រង់ជីវិតដំណាំទាំងពួងបានដោយបរិបូណ៌ មួយទៀតកំទេចកំទីនៃរុក្ខជាតិ ដែលក្រាលនៅលើផែនដីក៏ជាដីដ៏សំខាន់ណាស់ដែរ ៗ ដុំសិលាតូច ៗ ឬធំនៅរាយគ្នាក្ដី នៅជុំគ្នាក្ដីហៅថាដុំថ្មដា ៗ ដីខ្សាច់គឺជាកំទេចផង់ធូលីថ្មដា ដីបែបនេះមានកម្រាស់ប្រហែល ៦០ គី-ឡូម៉ែត្រ ៗ នៅក្នុងដីមានចំហាយក្ដៅជាងនៅលើផ្ទៃផែនដី កាលណាគេចុះទៅក្នុងអណ្ដូង គេសំគាល់បានថានៅក្នុងដីក្ដៅជាងផ្ទៃផែនដីមួយកំរិតក្នុងជំរៅប្រហែល ៣០ម៉ែត្រ ៗ នៅកន្លែងខ្លះមានដីម៉ដ្ឋស្អិត ទឹកពុំអាចជ្រាបចូលបានឡើយ ហៅថាដីឥដ្ឋ គេប្របាច់កិនដីនេះនឹងដៃបានដោយងាយ ហេតុនេះ ហើយបានជាគេយកដីឥដ្ឋនេះទៅធ្វើជាក្អមឆ្នាំង និងប្រដាប់

ប្រជាផ្សេងៗសំរាប់មនុស្សយើងត្រូវការប្រើ ។ មានថ្មខ្លះរឹងហើយល្អណាស់ មានពន្លឺផ្សេងៗ ហៅថាថ្មដុំ គេយកទៅធ្វើជាត្បូង ។ មានថ្មខ្លះទៀតផុយ បែកពុះរលាយក្នុងទឹកម្សូរគេហៅថាថ្មកំបោរ ថ្មទាំងអស់នេះសឹងនៅក្នុងកម្រាស់ផែនដី ។ល។

មេរៀនសង្ខេប .— ព្រះធរណីរាងមូល ហើយសំប៉ែតបន្តិចនៅត្រង់ចុងទាំងសងខាង ។ នៅក្នុងដីមានធាតុគ្រប់យ៉ាង នៅស្រទាប់លើបង្អស់ជាដីមានជីជាតិ គេដាំដំណាំបានគ្រប់ដំពូក សំរាប់ជាអាហារឬជាសិប្បិយការផ្សេងៗ ។ នៅសន្ទាប់ទីពីរមានដីខ្សាច់ឬដីឥដ្ឋតាមដោយដំបន់ដី នៅសន្ទាប់ទីបីមានក្រួសឬថ្មជា ។ នៅក្នុងដីមានចំហាយក្ដៅជាងនៅលើផ្ទៃផែនដី គេសំគាល់បានថាក្នុងជំរៅប្រហែល ៣ ម៉ែត្រមានចំហាយក្ដៅឡើងរើសមួយកំរិតៗ ដីមិនដូចគ្នាទាំងអស់ទេ នៅកន្លែងខ្លះមានដីម៉ដ្ឋហើយស្អិតដូចម្សៅ ទឹកជ្រាបចូលពុំបានគេហៅថាដីឥដ្ឋ គេយកដីនេះទៅធ្វើក្អម ឆ្នាំង ពាង ។ល។ នៅកន្លែងខ្លះមានថ្មផុយ ហៅថាថ្មកំបោរ នៅកន្លែងខ្លះទៀតមានថ្មមានពន្លឺផ្សេងៗហើយមានពណ៌គ្រប់យ៉ាង ហៅថាថ្មត្បូង ។ ថ្មទាំងនោះសឹងនៅលើដីឬក្នុងដី ។

ពាក្យសួរក្នុងមេរៀន .— ព្រះធរណីមានរាងដូចម្ដេច ? នៅក្នុងដីមាន

អ្វីខ្លះ ? នៅសន្ទាប់លើបង្អស់ដូចម្ដេច ? ដីភានសណ្ឋានដូចម្ដេចនៅសន្ទាប់ទីពីរ ? ទីបី ? ដីមានសណ្ឋានដូចគ្នាទាំងអស់ឬទេ ? នៅលើផែនដីមានថ្មអ្វីខ្លះ ? ។ល។

## វិធីបង្ការរោគ

**មេរៀនក្នុងខែ** .- ១ អំពីការថែរក្សាក្អក ។ ២ ការថែរក្សាត្រចៀក ។

៣- អំពីដកដង្ហើម ។ល។

សូមមើលហើយបង្រៀនតាមសៀវភៅ វិធីបង្ការរោគទំព័រទី១៥ដល់១៨ ។

**មេរៀនជាគំរូ** .- អំពីការដកដង្ហើម ។

**ការហាត់** .- ១. ទម្លាប់សិស្សឲ្យបើកទ្វារបង្អួច កន្លែងរៀនយ៉ាងធំ នៅពេលរៀនក្ដី ពេលឈប់សម្រាករៀនក្ដី ។

២- នៅវេលាហាត់ប្រាណរាល់ថ្ងៃ ឲ្យសិស្សរៀនដកដង្ហើមជានិច្ច នៅពេលខាងចុងមុនឈប់បង្ហាត់ពលវិធី ។

៣- ទម្លាប់សិស្សឲ្យដកដង្ហើមតែតាមច្រមុះ ហើយដកដង្ហើមចូលឲ្យបានវែងៗផង ។ល។

មេរៀន :

ប្រយោជន៍ឲ្យបានសេចក្ដីសុខសប្បាយ ត្រូវតែបេះដកដង្ហើម ហើយដកដង្ហើមតែខ្យល់អាកាសល្អផង ។

យើងត្រូវបេះដកដង្ហើម.– យើងមិនត្រូវដកដង្ហើមតាមមាត់ទេ ហើយពុំត្រូវដកដង្ហើមញាប់ពេកឡើយ ។ យើងត្រូវតែដកដង្ហើមតាមច្រមុះ ឲ្យស្រួលហើយឲ្យបានវែងៗផង ។ កុំដកដង្ហើមតាមមាត់ឲ្យសោះ ។ ការដកដង្ហើមតាមច្រមុះនេះបណ្ដាលឲ្យមានអាកាសក្ដៅ ដើម្បីសម្លាប់មេរោគទាំងតូចដែលចូលទៅក្នុងសួតយើង ។ ហេតុនេះត្រូវដកដង្ហើមឲ្យវែងៗប្រយោជន៍ផ្លាស់ប្ដូរធាតុអាកាសនៅក្នុងសួត ។

យើងត្រូវតែដកដង្ហើមនៅអាកាសល្អ.– អាកាសល្អដែលយើងត្រូវយកម្ដង ៗ ដើម្បីឲ្យបានសេចក្ដីសុខក្សេមក្សាន្តនោះ គឺនៅមាត់សមុទ្រ នៅលើភ្នំ នៅស្រុកស្រែចំការហើយឲ្យឆ្ងាយអំពីទីស្មោកគ្រោកផង ។ នៅកន្លែងណាដែលមានអាកាសមិនល្អ បណ្ដាលឲ្យយើងឈឺក្បាលខ្យល់ចាប់មួយរំពេចពុំខានឡើយ ។ បន្ទប់ណាដែលមានមនុស្សច្រើនត្រូវតែផ្លាស់ប្ដូរអាកាសជាញយៗដោយបើកទ្វារបង្អួចឲ្យខ្យល់ចូលជារឿយ ៗ

ចូរយើងទម្លាប់ទៅកណ្ដាលផ្លាខ្យល់អាកាស តែត្រូវឲ្យដឹងថា បើកាលណាយើងបែកញើសចូរយើងកុំនៅកណ្ដាលអាកាសត្រជាក់ ។

យើងត្រូវដកដង្ហើមដូចម្ដេច.– យើងត្រូវដកដង្ហើមស្រូបយកខ្យល់បំរុងធាតុនេះឲ្យបានច្រើន ប្រយោជន៍ឲ្យឈាមដែលរត់ក្នុងខ្លួនយើងនៅស្រស់ល្អ ។ បើសិនណាយើងដកដង្ហើមចូលបាន ១០ ដងយ៉ាងវែងៗក្នុងមួយថ្ងៃ នៅកណ្ដាលផ្លាខ្យល់អាកាស យើងនឹងបានជាមនុស្សឆ្លាតធ្វើតាមច្បាប់វិធីបង្ការរោគ ហើយនឹងបានសេចក្ដីសុខក្សេមក្សាន្ត ព្រមទាំងបានអាយុវែងផង ។

មេរៀនសង្ខេប .– សូមលោកគ្រូតែងមេរៀនសង្ខេបនឹងពាក្យសួរផងចុះ ។ ការតែងមេរៀនសង្ខេបនេះ តាមក្បួនគរុកោសល ត្រូវតែធ្វើជាមួយនឹងសិស្សទើបបានល្អ ហើយល្មមនឹងកម្លាំងសិស្សផង ។

---

## **អាទិកដ្ឋន**

### វត្ថុស្វាធ្យាយន៍

អាទិត្យទី១. – ដីសនឹងថ្មកំបោរ ។

សុំមើលសៀវភៅវត្ថុស្វាធ្យាយន៍សំរាប់អាទិកដ្ឋានទំព័រ៤៨ ៤៩ ៥០ ។

## អាទិត្យទី២.- ដីឥដ្ឋនឹងការធ្វើឥដ្ឋធ្វើក្បឿង ។

សុំមើលសៀវភៅវត្ថុស្វាធ្យាយន៍សំរាប់អាទិកដ្ឋានទំព័រ១១៦ ១១៧ ។

## អាទិត្យទី៣.- អំបិលនឹងកែវ ។

### មេរៀនទី១.- អំបិល (សុំមើលសៀវភៅវត្ថុស្វាធ្យាយន៍អាទិ-កដ្ឋានទំព័រ ១១៤,១១៥ ។

### មេរៀនទី ២ .- កែវ

ក ) ការធ្វើកែវ.– គេលាយដីខ្សាច់ជាមួយនឹងអំបិលមួយយ៉ាងហៅថា " សូ៊ត " ហើយនឹងផង់ដីសយ៉ាងម៉ដ្ឋ ហើយដុតវត្ថុទាំងនេះក្នុងឡយ៉ាងក្តៅ ៗ វត្ថុនេះរលាយទៅជាវត្ថុរាវដែលគេអាចយកទៅចាក់ពុម្ពធ្វើអ្វីៗបានតាមចិត្ត ។

ខ )- លក្ខណរបស់កែវ - ការប្រើប្រាស់កែវ

១ – កែវមានសាច់ថ្លាធ្ងន់ (អាចធ្វើជាកញ្ចក់) កែវវែនតា .... តែគេអាចធ្វើឲ្យមានជាពណ៌ផ្សេងៗបាន ។

២ – កែវមានសាច់រឹងណាស់ យើងពុំអាចធ្វូតនឹងក្រចកឬនឹងកាំបិតដាច់ឡើយ ។

គេកាត់កញ្ចក់បានដោយថ្មពេជ្រឬនឹងដែកថែបយ៉ាងរឹង ។

៣ – កែវមានសាច់ស្រួយ, ធ្លាក់ឬត្រូវភ្លើងក្តៅបែក ។

៤ – កែវបញ្ចេញសូរខ្ទរកាលណាគេគោះ -

## អាទិត្យទី៤.– អណ្តូងយកប្រេង ប្រេងសំរាប់ដុត ការដឹកយកធ្យូងថ្ម។

សុំមើលក្នុងសៀវភៅវត្ថុស្គាល់ព្យាយន៍សំរាប់អាទិកដ្ឋានទំព័រ. ១២៣ ១២៤ . ១២៥. ។

## វិធីបង្ការរោគ

## អាទិត្យទី១.– ជម្ងឺគ្រុនចាញ់

សុំមើលទស្សនាវដ្តីឆ្នាំនេះខែមករា ត្រង់ទំព័រសំរាប់មធ្យមដ្ឋានទី១

## អាទិត្យទី២.– ជម្ងឺពិសបាកាំងហៅថាប៉េស្ត

**គោលសេចក្តី.–** ជាជម្ងឺរាតត្បាតតែងចូលមកពីប្រទេសចិនតាមទូកដោយសារកណ្តុរ ៗ កើតមានជានិច្ចនៅឃុំនណាងទឹងនៅប្រទេសកូឈិ ៗ

១) លក្ខណៈ - ឡើងក្នុងកណ្ដុរប៉ុនពងមាន់នៅត្រង់ក្លៀក និង ត្រង់ក្រលៀន អ្នកជម្ងឺគ្រុនសន្លប់សន្លិន ។

២) ហេតុ.- បណ្ដាលពី "អតិសុខុមប្រាណយែរសាំង" តែង កើតលើរូបកណ្ដុរនៅក្នុងដី ហើយឆ្លងមកមនុស្សដោយចៃខាំ ។ ខ្ទុះ ក្នុងកណ្ដុរដែលហើមនៅក្លៀកនិងក្រលៀន មានមេរោគច្រើនក្រៃលែង ខ្ទុះនេះនាំឲ្យឆ្លងកុតឆាប់ណាស់ ។

៣) កិច្ចការពារ .-

ក ) ឲ្យមនុស្សជម្ងឺនៅដោយឡែក ។

ខ ) ដាក់លាមកនិងទឹកមូត្រក្នុងកន្ថោរមានទឹក "ក្រេស៊ីល" ហើយ ចាក់កប់ក្នុងរណ្ដៅជំរៅ១ម មានលាយកំបោរផង ។

គ ) កប់ខ្មោចស្លាប់និងជម្ងឺនេះ ក្នុងរណ្ដៅជំរៅ ២ម ចាក់កំបោរពីលើផង ។

ឃ ) ឆាបផ្ទះនិងទឹកកំបោរ - ស្ងោរប្រដាប់ដែលអ្នកជម្ងឺប្រើ ។

ង ) ត្រូវចាក់ថ្នាំ ។

ច ) សំឡាប់កណ្ដុរហើយដុតចោល ។

អាទិត្យទី៣.- ត្រូវធ្វើកុំឲ្យមានចៃ

សុំមើលក្នុងសៀវភៅវិធីបង្ការរោគទំព័រ ៤៦-៤៧-៤៨. ។

## អាទិត្យទី៤.– ជម្ងឺកមរមាស់

គោលសេចក្ដី.– ជាជម្ងឺសើស្បែកឆ្លងបានដោយងាយ ៗ

១ លក្ខណៈ–ដំបូងរមាស់– មានកន្ទួលត្រង់ចង្អៀកម្រាមដៃ, កដៃ, កែងដៃរួចពេញខ្លួន ៗ

២ ហេតុ.– បណ្ដាលពីសុខុមសត្វរាងដូចសត្វពីងពាង ៗ ញីវាពងក្នុងសាច់បង្កើតជាកូនបានឆាប់ណាស់ ៗ

៣_កិច្ចការពារ.–

ក) កុំឲ្យអេះ ៗ

ខ) ដុសខ្លួនទឹកសាប៊ូក្ដៅ ដោយគួតយ៉ាងខ្លាំង ដើម្បីកំចាត់ពងមេរោគចេញ រួចលាបថ្នាំដែលមានលាយស្ពាន់ធ័រ ផ្អាប់ចោល ស្អែកឡើងសឹមលាងទឹកក្ដៅចេញ ៗ

គ) ស្លៀកពាក់តែខោអាវដែលស្ងោរស្អាត ៗ

---

## មជ្ឈិមដ្ឋាន ទី១

## វិត្តស្វាធ្យាយន៍

## អាទិត្យទី១.– ជី

គោលសេចក្តី ជីមានបួនយ៉ាងគឺ៖

១ ជីកើតពីសត្វពាហនៈ – ជាជីវិសេសបំផុតកើតពីលាមកសត្វលាយទឹកចំបើង អង្កាម អាចម៍រណា, ស្លឹកឈើងាប់ ត្រូវទុកជីនេះឲ្យរលួយលើផែនដីដែលមិនជក់ទឹក ហើយធ្វើពេងការពារកុំឲ្យត្រូវកំដៅថ្ងៃ ។ ម្យ៉ាងទៀតគេត្រូវស្រោចជីនេះនឹងទឹកនោមសត្វផង ។

២ – ជីកើតពីសត្វ – គឺអាចម៍ប្រចៀវ, សត្វស្លាប, កាកត្រី, ដឹកដៀ, កំទេចស្បែក, ឆ្អឹង, ឈាមកក ។

លាមកមនុស្សជាជីមួយបែបល្អបំផុតតែប្រើទៅតែងបណ្តាលឲ្យមានគ្រោះថ្នាក់ផ្សេងៗមកពីមានមេរោគជាប់ជាមួយនោះ ។ គេនឹងប្រើជីជំពូកនេះបានឥតទោស លុះត្រាតែទុកលាមកឲ្យរលួយអស់ក្នុងរណ្តៅមួយ យ៉ាងជិត ឬ ហាលថ្ងៃឲ្យស្ងួតហើយកិនឲ្យខ្ទេច ។

៣ – ជីកើតពីរុក្ខជាតិ កើតពីរុក្ខជាតិស្លឹកច្រើនដែលគេដាំក្នុងស្រែចំការហើយដែលគេកាប់កប់នៅទីនោះ នៅពេលដែលរុក្ខជាតិនេះកំពុងបែកផ្កា ។ គេប្រើកាកប្រេងនឹងផេះដែរ ។

៤ — ដីកើតពីសិលាជាតិ — ដីជំពូកនេះមានកើតឯងក្នុងព្រះធរណី ឬគេធ្វើលក់ក្នុងរោងឧស្សាហកម្ម ។

## អាទិត្យទី ២.— ការបង្ហូរទឹកចូលនិងបង្ហូរទឹកចេញ ។

១ — ប្រយោជន៍ទឹក — ទឹកមានប្រយោជន៍ក្នុងការផ្គត់ផ្គង់ជីវិតរុក្ខជាតិណាស់ តែរុក្ខជាតិទាំងឡាយមិនត្រូវការទឹកដូចគ្នាឡើយ ខ្លះត្រូវការដីគោក, ខ្លះដីសើម, ដុះក្នុងទឹក ។

២ — ការបង្ហូរទឹកចូល - ក្នុងច្បារគេស្រោច - ក្នុងស្រែ - ចំការគេបាចទឹកបញ្ចូលដោយស្នាច, កញ្ជើថ្នាំង, យោង, ចូង, ឬរហាត់ទឹក ។

៣ — ការបង្ហូរទឹកចេញ - ក្នុងស្រែចំការដែលមានដីដក់ទឹក នាំឲ្យខូចដំណាំ គេត្រូវបង្ហូរទឹកចេញ ។ គេធ្វើដូចរបៀបបង្ហូរទឹកចូលដែរ ជួនកាលគេកប់បំពង់បង្ហូរទឹកក្រោមដី ។

## អាទិត្យទី៣និងទី៤ .— ដំណាំសំខាន់ផ្សេងៗក្នុងស្រុក .

សុំគ្រូចាត់ចែងបង្រៀនតាមសៀវភៅ វត្ថុស្វាធ្យាយន៍សំរាប់អានទុកដ្ឋានពីទំព័រ ៦៧ ដល់ ៧៤ ផងចុះ ។

# វិធីបង្ការរោគ

## ជម្ងឺអាសន្នរោគ

អាសន្នរោគជាជម្ងឺឆ្លងអាចរាតត្បាតមនុស្សទាំងភូមិៗឲ្យស្លាប់បានៗ ជម្ងឺនេះមានជានិច្ចជាកាលនៅប្រទេសក្លិង្គ ហើយបានបំផ្លាញជីវិតមនុស្សជាច្រើន, នៅប្រទេសចិននិងឥណ្ឌូចិន ៗ កាលពីឆ្នាំ ១៩២៦-២៧ជម្ងឺនេះធ្វើឲ្យវិនាសជីវិតមនុស្សនៅឥណ្ឌូចិនអស់ ១២.០០០ នាក់ ៗ

១– លក្ខណៈ – រាគរូសខ្លាំង(២០ ច្បាយដងក្នុង ១ថ្ងៃ) ៗ លាមកសុទ្ធតែទឹក ហើយមានកំទេចរំងសដូចជាគ្រាប់អង្ករ ទឹកមូត្រថយ ស្បែកត្រជាក់ អ្នកជម្ងឺឈឺចាប់ក្នុងខ្លួនតិចណាស់ ប៉ុន្តែចេះតែស្រេកទឹកហើយក្អួតជាញយៗ អ្នកជម្ងឺឆាប់ហេវណាស់ហើយស្លាប់ក្នុងរវាង២-៣ថ្ងៃឬ៤-៥ម៉ោងក៏មាន ៗ

២– ហេតុ– ជម្ងឺនេះបណ្ដាលពី "អតិសុខុមប្រាណកើតនៅក្នុងពោះវៀន រាងដូចកណ្ដក់សញ្ញា ៗ អតិសុខុមប្រាណនេះឆ្លងពីមនុស្សមួយទៅមួយ ដោយទឹក, បន្លែឆៅ,លាមក, សត្វល្អិតហើយគ្រឿងដែលអ្នកជម្ងឺប្រើប្រាស់ ៗ

### ៣– កិច្ចការពារ .–

ក)– ត្រូវដាំទឹក,បំអិនបន្លែ ហើយគ្របចំណីអាហារកុំឲ្យរុយទំ ។

ខ)– ត្រូវកាន់តាមវិធីបង្ការរោគឲ្យណាស់ៈ ចៀសវាងកុំឲ្យធ្វើអ្វីឲ្យខ្សោយកម្លាំង ។ ត្រូវលាងដៃឲ្យស្អាតមុនពេលបាយ ។

គ)– ត្រូវឲ្យពេទ្យចាក់ថ្នាំ ដែលជាកិច្ចការពារជម្ងឺនេះ កុំឲ្យរាត-ត្បាតបាន ។

### ៤– កិច្ចត្រូវធ្វើចំពោះមនុស្សកើតអាសន្នរោគ.–

ក)– ត្រូវដាក់មនុស្សជម្ងឺនឹងពួកគ្រួសារនៅដោយឡែក ទុកឲ្យតែមនុស្សម្នាក់ចេញចូលមើលការខុសត្រូវ ។

ខ)– ឲ្យមនុស្សជម្ងឺបន្ទោបង់លាមកនឹងទឹកមូត្រក្នុងកន្តោរដែលមានលាយទឹក “ គ្រេស៊ីល ” រួចយកទៅចាក់កប់ក្នុងរណ្តៅជំរៅ១ម ដោយមានចាក់កំបោរ ពីលើផង ។

គ)– កប់ខ្មោចស្លាប់ដោយជម្ងឺនេះក្នុងរណ្តៅជំរៅ២ម៉ ជីកឲ្យឆ្ងាយពីផ្លូវទឹកទាំងឡាយ ហើយចាក់កំបោរពីលើ ។

ឃ)– បាចទឹកកំបោរពាសពេញផ្ទះ: – គ្រឿងប្រដាប់ដែលមនុស្សជម្ងឺបានប្រើប្រាស់ទាំងប៉ុន្មាន គោងស្ងោរឬបាចទឹក “ គ្រេស៊ីល ” ។

# កុមារដ្ឋាន

## វត្ថុស្វាធ្យាយន៍ ៖

### អាទិត្យទី ១ .– អំពីលោហធាតុ

សូមគ្រូយកកំណាត់ដែក ស្ពាន់ ស្ពាន់ស សំណ សំណប៉ាហាំង ស័ង្កសី ប្រាក់ មាស មកបង្រៀន ។

ដូចម្ដេចហៅថាលោហធាតុ គឺស្ពាន់ សំណ សំណប៉ាហាំង ស័ង្កសី ប្រាក់ មាស ត្រូវយកវត្ថុនេះមកបង្ហាញសិស្សឲ្យពិនិត្យ ។

### លោហធាតុកើតក្នុងដី

លោហធាតុនៅទីណា ? នៅជ្រៅក្នុងដី ។ ធ្វើដូចម្ដេចដើម្បីនឹងយកមកពីក្នុងដីបាន ? គេជីកជាអណ្ដូងជ្រៅគាស់កកាយយកមក ។ លោហធាតុនៅក្នុងដីសុទ្ធឬទេ ? មានសុទ្ធខ្លះដែរ.(មាស ប្រាក់) ប៉ុន្តែច្រើនតែលាយនឹងវត្ថុឯទៀតៗ ។

**.លោហធាតុមានពន្លឺ យកថ្មមួយដុំ ប្រាក់មួយដុំមកឲ្យសិស្សពិនិត្យ**

មើល ៗ វត្ថុណាមានពន្លឺ ? លោហធាតុទាំងអស់ សុទ្ធតែមានពន្លឺពិត ច្រើនក្តី ជួនកាលមានពន្លឺនោះក៏រលុបដោយព្រោះចាប់ ស្នឹម ៗ

លោហធាតុដុំបត់បែនឬហូតជាខ្សែបានទាំងអស់ ៗ

ឯងទាំងអស់គ្នាដែលចូលទៅមើលក្នុងរោងជាងដែកឬទេ ? ជាង ដែកពត់បត់ដែកបានដូចម្តេចខ្លះ ? ដំបានជាដុំជាបន្ទះឬជាវត្ថុជាច្រើន ផ្សេង ៗ តាមចិត្តបាន ៗ

ដែក មាស ប្រាក់ហូតជាខ្សែបានឬទេ ? ជាងទង់ហូតប្រាក់បានដូចម្តេច លោហធាតុជាប់ណាស់ ឲ្យសិស្សបណ្តាច់ខ្សែលួសហើយនិងខ្សែអំបោះ ប៉ុនគ្នា ៗ ខ្សែណាជាប់ជាង ? បើគេចង់សង់ស្ពានមួយយ៉ាងមាំត្រូវ សង់នឹងដែកឬមួយនឹងឈើ ? លោហធាតុរលាយដោយកំដៅទាំងអស់ ៗ

បើយើងយកសំណប៉ាហាំងមួយដុំ ទៅដុតក្នុងកូនចែង ដុំនោះក្លាយ ទៅដូចម្តេច ? ជាងទង់រលាយមាសនឹងកំដៅភ្លើងអ្វី ? លោហធាតុ ណាឆាប់រលាយជាងគេ ? លោហធាតុនាំកំដៅឆាប់ណាស់ បើអ្នកយក ដែកមួយដុំទៅដុតក្នុងភ្លើង ហើយអ្នកកាន់ចុងម្ខាងនៅដៃ, តើអ្នកកាន់ បានយូរដែរឬទេ ? ពីព្រោះអ្វី ? ពីព្រោះលោហធាតុនាំចំហាយកំដៅបាន ឆាប់ណាស់ ៗ ហេតុដូចម្តេចបានជាគេចូលចិត្តប្រើឆ្នាំងដែក ឆ្នាំងស្ពាន់ ជាងឆ្នាំងដី ? ៗ

សេចក្ដីសង្ខេប ៖ លោហធាតុគឺ ដែក ស្ពាន់ សំណ ស័ង្កសី ទង់ហ្គី ទង់ដែង មាស ប្រាក់ លោហធាតុកើតនៅក្នុងដី ។ លោហធាតុទាំងអស់មានពន្លឺ ដំ បត់បែន ហូតជាខ្សែបាន លោហធាតុជាប់មាំ រលាយបាន ហើយនាំចំហាយក្ដៅណាស់ ។

## អាទិត្យ ទី ២.– អំពីធ្យូងថ្ម

វត្ថុសំរាប់បង្រៀន-កាំបិតបត់ ញញួរ ធ្យូងថ្ម ធ្យូងឈើ កាកធ្យូងថ្ម ។

នាំសិស្សពិនិត្យមើលធ្យូងថ្ម ពណ៌ដូចម្ដេច ? យកកាំបិតទៅកាត់ធ្យូង ។ សង្កេតឃើញដូចម្ដេច ? ធ្យូងថ្មមិនសូវរឹងទេ ។ យកញញួរវាយធ្យូងមួយដុំតូច សង្កេតឃើញដូចម្ដេច ? ឃើញថាធ្យូងថ្មផុយមែន ធ្យូងថ្មឆេះ ដុតធ្យូងថ្មមួយដុំនៅលើអំបែងមួយ ធ្យូងនោះឡើងក្រហមច៉ោងរឿងហើយឆេះមានចំហាយខ្លាំង ធ្យូងថ្មគឺជារបស់មួយយ៉ាងសំខាន់ គេប្រើការដូចម្ដេចខ្លះ ? គេដុតឡពេងម៉ាស៊ីន គេដុតខ្លះកប៉ាល់ ។

កំណើតធ្យូងថ្ម-នៅលើធ្យូងថ្មគេច្រើនឃើញស្នាមសន្លឹកដើមឈើ ហេតុដូច្នេះបានជាដឹងថាធ្យូងថ្មកើតមកអំពីដើមឈើ ដែលកប់នៅក្នុងដីជាច្រើនពាន់ឆ្នាំមកហើយ ។

ការជីកយកធ្យូងថ្ម - ធ្យូងថ្មមាននៅឯណា ? មាននៅក្នុងដីសណ្ដានជាស្រទាប់ ៗ មានចំនួនរាប់គីឡូទទឹងបណ្ដោយ ៗ ដើម្បីនឹងយកធ្យូងថ្មពីក្នុងដី គេជីកជារូងជ្រៅទៅក្នុងដីហើយកកាយជីកយកធ្យូងនោះមក ៗ ធ្យូងមានច្រើនយ៉ាង ៗ គឺធ្យូងថ្មដែលសំរាប់ដុតមានពណ៌សថ្លាកើតឡើងនៅក្នុងដី ៗ នៅក្នុងព្រៃឈើយកឧសទៅរៀបដុតក្នុងឡកើតបានជាធ្យូងហៅថាធ្យូងឈើ ៗ

## អាទិត្យទី៣.- អំពីអំបិល

វត្ថុសំរាប់បង្រៀន.- អំបិលខ្មៅ អំបិលស កែវ ចាន ត្រីប្រលាក់

អំបិលខ្មៅ - ជាគ្រាប់ដុំពណ៌ប្រផេះ ៗ អំបិលមានជាតិប្រៃអាចនឹងឲ្យរសដល់អាហារយើង ៗ

អំបិលនឹងទឹក - ត្រូវខ្យល់សើមអំបិលរលាយ ហេតុដូច្នេះត្រូវទុកក្នុងប្រអប់បិទជិតឬក្នុងពាងទើបបានគង់ ៗ

អំបិលដាក់ទៅក្នុងទឹករលាយបាត់រូប បើយកទឹកប្រៃនេះទៅហាលថ្ងៃ ទឹកហួតអស់ទៅនោះឃើញអំបិលឡើងវិញ កកនៅបាតចាន ៗ

ស្រែអំបិល - ទឹកសមុទ្រប្រៃព្រោះអំបិល ដើម្បីយកអំបិល គេ

បណ្តាលទឹកសមុទ្រទៅក្នុងស្រែ ៗ ដល់ត្រូវកំដៅថ្ងៃទឹកហួតទៅនៅសល់គ្រាប់អំបិល ៗ គេកើបយកមក ៗ

អំបិលស  នៅក្នុងដីមានគំនរអំបិលសកើតឡើងមកអំពីទឹកសមុទ្រដែលហួតក្នុងដី  ដើម្បីនឹងយកអំបិលនេះគេជីករូងគាស់យកអំបិលនេះឡើង ៗ

ប្រយោជន៍អំបិល – ផ្សំជាតិអាហារ ប្រឡាក់ត្រីសាច់ ធ្វើជាក្បុងស្ងោរខោអាវ ៗ

អាទិត្យទី ៤.– ១– អំពីសីលា

២– អំពីសិប្បិយការសីលា

៣– អំពីអណ្តូងយកសីលា

## វិធីបង្ការរោគ

អាទិត្យទី១.– ការសំអាតបន្ទប់រៀន

សេចក្តីពន្យល់ - បន្ទប់រៀនគឺជាទីកន្លែងមួយ ដែលត្រូវតែឲ្យស្អាតជាដរាប នាំឲ្យបានសេចក្តីសុខសប្បាយដល់ខ្លួន បើយើងសំអាតតែរូបកាន

កាយយើង ឯកន្លែងដែលយើងអាស្រ័យនៅរាល់ថ្ងៃកខ្វក់នោះ យើងក៏មិនបានសុខសប្បាយស្កិតស្កើរដែរ ។ ដូច្នេះយើងត្រូវបោសសំអាតបន្ទប់រៀនយើងរាល់ថ្ងៃទើបប្រពៃ ។ បន្ទប់រៀនត្រូវឲ្យស្ងួតឲ្យល្ហើយមានខ្យល់បក់ចេញចូលជានិច្ច ឲ្យមានពន្លឺព្រះអាទិត្យបរិបូណ៌ ហើយឲ្យស្អាត ។ បើបន្ទប់រៀននៅផ្ទាល់ទឹងដី យើងត្រូវបុកដីឲ្យហាប់កុំឲ្យមានក្រហេងក្រហូងឬដុំដីរដិបរដុប ដើម្បីកុំឲ្យដក់ទឹក ។ ដកស្មៅចោលឲ្យអស់ - កុំឲ្យមានដុះនៅក្បែរជញ្ជាំង បើជាបន្ទប់សង់ខ្ពស់អំពីដីឬក្រាលឥដ្ឋនោះការសំអាតងាយណាស់ ។

សូមគ្រូតែងពាក្យចោទផងចុះ ។

## អាទិត្យទី២.– ការបោសច្រាស់

សេចក្តីពន្យល់ - យើងត្រូវបោសច្រាស់បន្ទប់រៀនរាល់ថ្ងៃ ពេលព្រឹកមុនចូលរៀនឬពេលល្ងាចវេលាទៅផ្ទះ បើបន្ទប់នៅផ្ទាល់ទឹងដី យើងប្រើអម្បោសរឹង បើបន្ទប់ក្រាលក្តារឬឥដ្ឋវិញ យើងប្រើអម្បោសស្រកីដូង ។ មុនដឹងបោសត្រូវស្រោចទឹកឲ្យសព្វកន្លែង យើងបោសឲ្យល្មមមិនត្រូវរាសអម្បោសនោះខ្លាំងទេ ដើម្បីកុំឲ្យធូលីហុយឡើងបាន ។ យើងត្រូវបោសគ្រប់តំបន់កន្លៀតកន្លែងកុំឲ្យសល់ ។

ប្រមូលសំរាមដាក់មួយដុំ - កើបយកទៅចោលនៅកន្លែងចាក់សំ-រាម លុះចោលស្រេចហើយ បើបន្ទប់ក្រាលក្តារឬឥដ្ឋត្រូវយកចារជ្រ-លក់ទឹកឲ្យសើមទៅជូតថែមទៀត ។

ចូរកុំភ្លេចបោសសំបុកពីងពាងនៅជញ្ជាំងនឹងពិតាននឹងបោសព្រាសក្រោមតុទូផង ។

អាទិត្យទី ៣.– អំពីបោសធូលីប្រមូលក្រដាស កន្ត្រកដាក់ក្រដាស មិនត្រូវដាក់ក្រដាសក្នុងថតតុ ។

អាទិត្យទី ៤.– ត្រូវឲ្យមានខ្យល់អាកាស ត្រូវឲ្យមានពន្លឺល្មមៗ បង្រៀនសាឡើងវិញ ។

---

# បរិច្ឆណាដ្ឋាន

## វត្ថុស្វាធ្យាយន៍

អាទិត្យទី១.- ១.– អំពីសំពត់

វត្ថុសំរាប់បង្រៀន.—ផ្ទុកបង្ហាសទុំ. អំបោះ ខ្សែអំបោះ សំឡី កំណាត់សំពត់ច្រើនយ៉ាង ។

ការវៃអំបោះ — គេយកផ្លែកប្បាសទុំទៅធ្វើឲ្យជ្រុះគ្រាប់នៅសល់តែសំឡី ៗ គ្រូនាំសិស្សពិនិត្យមើលសរសៃសំឡីដែលឆ្មារ ៗ ទាញយកសរសៃពីរឬបីហើយគ្របាញ់នឹងដៃ បានជាអំបោះនាំសិស្សយកអំបោះមួយសរសៃមកលាមើលសរសៃសំឡី ។ ដើម្បីនឹងវេញជាអំបោះដូច្នេះបានស្រួល អ្នកត្បាញមានរហាតមួយវិលទាញយកសរសៃសំឡីនោះមកវេញជាអំបោះ ៗ

ការត្បាញសំពត់ — យកកំណាត់សំពត់មកឲ្យសិស្សពិនិត្យមើលសរសៃអំបោះដែលត្បាញហូតអំបោះចាក់មួយម្ដងៗបង្ហាញសិស្សមើល ៗ

៤— អំពីសរសៃឯទៀតដែលត្បាញជាសំពត់

វត្ថុសំរាប់បង្រៀន— ដើមឬសំបកធ្មៃ- ក្រចៅស្មាច់ ធាងម្នាស់ ខ្សែធ្មៃ ឬក្រចៅ បារ ៗ

ការត្រាំក្រចៅ ដល់ដើមក្រចៅចាស់គេកាត់ចុងដើមចងជាបាច់ ហើយយកទៅត្រាំទឹកស្អុំ ឬត្រពាំង ដើម្បីឲ្យជ័រដែលភ្ជាប់សំបកទៅនឹងសាច់ដើមនោះរលាយ ៗ

ការហូតសរសៃ - ដល់ហាលថ្ងៃរួចគេដំ ឬ កិន សរសៃសំបករបកចេញពីដើម គេបំបែកជាសរសៃឆ្មារ ឯសរសៃនេះគេយកទៅវេញជាអំបោះហើយទៅត្បាញជាសំពត់ ឬ មួយវេញជាខ្សែ ៗ

សំពត់ក្រហៅក្រាស់ហើយជាប់  គេធ្វើជាបាវដាក់ស្រូវ ពោត ។

ឯធ្មៃ ស្មាច់ ក៏ធ្វើរបៀបយ៉ាងនេះដែរ  សរសៃសម្លាស់ត្បាញបាន ជាសំពត់យ៉ាងល្អ ។

អាទិត្យទី ២ ·— ១ អំពីត្បាញកន្ទេល

វត្ថុសម្រាប់បង្រៀន — ដើមកក់ស្រស់ កក់ស្ងួត កក់ជ្រលក់ កន្ទេល កក់ពីរបីយ៉ាង កន្ទេលស៊ូកគោត កន្ទេលរំបេក កន្ទេលផ្តៅ ។

ដើមកក់មានដុះនៅមាត់បឹងឬមាត់ត្រពាំង  គេកាត់ចុងដើមកូតបន្ទះ ធ្មារ ។ រួចយកមកហាលថ្ងៃឲ្យស្ងួត ដល់ស្ងួតហើយទើបយកទៅជ្រលក់ពណ៌ រួចយកមកត្បាញ ។

ឯខ្សែអន្ទងគឺខ្សែធ្មៃ បើចង់ធ្វើៈគោមឬផ្កា គេគោងចាក់កក់ផ្លាស់ ពណ៌គ្នា ។ គេយកកក់មកត្បាញ កើតជាកន្ទេលបបួតឬកន្ទេលកន្ទ្រង កន្ទេលរំបេកធ្វើអំពីធាងរំបេក  កន្ទេលស៊ូកគោតធ្វើអំពីស៊ូកគោត ។ បើចង់បានកន្ទេលជាប់ប្រើបានយូរឆ្នាំ  គេយកបំរៀកផ្តៅមកត្បាញបាន ជាកន្ទេលហៅថាកន្ទេលផ្តៅ  ច្រើនមានធ្វើនៅស្រុកបាត់ដំបង ។

អាទិត្យទី៣,— កាស្រាវស្លឹត្រ

# អំពីត្បាញសំពត់សូត្រ

វត្ថុសំរាប់បង្រៀន– សំបុកដង្កូវនាង សូត្រដុំ សរសៃសូត្រ សំពត់សូត្រ សំពត់ព្រែឯទៀត ។

សូត្រដែលស្រាវយកមកពីសំបុកនាង គេយកមកវៃ នាំសិស្សពិនិត្យមើលសរសៃសូត្រឆ្មារៗ ហើយយកសរសៃនោះមកវេញនឹងដៃ សរសៃនេះវេញគួបគ្នាទៅបានជាសរសៃសូត្រយកមកត្បាញបាន ។

បើចង់បានពណ៌គេយកសូត្រទៅជ្រលក់ ឯរបៀបត្បាញនោះក៏ដូចជាត្បាញសំពត់អំបោះដែរ សូមគ្រូពន្យល់សិស្សរបៀបត្បាញម្តងទៀត ដើម្បីឲ្យសិស្សបានយល់ជាក់ច្បាស់ ។ ឯសូត្រគេត្បាញបានជាសារុង សំពត់ហូល ល្បើក ។ល។ សំពត់សូត្រនេះហៅថាសំពត់សូត្រសុទ្ធ ។

នៅផ្សារមានលក់សំពត់ព្រែច្រើនបែប ដែលមិនមែនជាសូត្រ ។

# អំពីសំពត់ធ្វើអំពីរោមចៀម

វត្ថុសំរាប់បង្រៀន រោមចៀម អំបោះចាក់ហើយនឹងអាវធ្វើអំពីរោមចៀម (សាក្លាត) .

នាំសិស្សពិនិត្យមើលសរសៃរោម សរសៃនេះធ្មារ ដូចជាសរសៃសំឡីកប្បាសឬសរសៃសូត្រ

ហេតុនេះបានជាគេយកមកធ្វើសំពត់បានដូចជាសំពត់កប្បាសឬសំ-ពត់សូត្រ ។

មុនដំបូងគេកាត់រោមនោះយកមកលាង លាបប្រេង សិតធ្វើជាបន្ទះមួយវែង រួចគេយកទៅដុសសាប៊ូហើយទាញជាអំបោះ រួចសិតទៀតដល់បានជាអំបោះគេយកមកត្បាញ ។

ឯរបៀបត្បាញនោះក៏ដូចជាត្បាញសំពត់ធម្មតា នាំសិស្សពិនិត្យមើលអំបោះធ្វើអំពីរោមចៀមហើយនឹងសំពត់សាក្លាត ។ អំបោះនេះគេយកមកបាក់ជាអាវយឺតក៏បាន ធ្វើជាភួយឬព្រំក៏បាន រោមពពែម្យ៉ាងហៅថាពពែ "អង្គុំ" ល្អជាងរោមចៀមទៅទៀត ។ សំពត់រោមចៀមឬរោមពពែ ក្រាស់ហើយក៏ក្ដៅ គេយកមកកាត់ខោអាវរងា ។

## អាទិត្យទី ៤.— អំពីជ្រលក់បំពត់

វត្ថុសំរាប់បង្រៀន.— មាក្លឿ មរ រមៀត សំបកខ្នុរ ល័ខគ្រប់មុខ ។

សាបង្រៀនពីដើមឡើងវិញ ។

# វិធីបង្ការរោគ

## អាទិត្យទី១ ២·– អំពីការសំអាតសំលៀកបំពាក់

សុំមើលសៀវភៅវិធីបង្ការរោគទំព័រទី ១៨ មើលឲ្យសិស្សស្ដាប់ហើយនិយាយពន្យល់សួរតាមពាក្យខាងក្រោមនេះ ៖

ពាក្យចោទសួរ.– បើឯងប្រើខោអាវតែមួយបង្កិះយូរ ថ្ងៃទៅឯងមានធុំក្លិនអ្វី ? ក្លិនអាក្រក់នឹងក្អែលបង្កើតមកអំពីអ្វី ? ខោអាវដែលមានញើសឬក្អែលគាត់ជានិច្ចនោះ ជាប់បានយូរឬទេ ? បើបង់ឲ្យខោអាវស្អាតត្រូវលាងរបៀបណា ? គេស្ងោរលាងសំអាតអាវដូចម្ដេច ? បើគ្មានសាប៊ូប្រើអ្វីជំនួសបាន គេលាយទឹកក្បួនភាគយ៉ាងណា ?

## អាទិត្យទី ៣.– ត្រូវស្លៀកពាក់ដូចម្ដេច

ពាក្យចោទសួរ·– ដូចម្ដេចបានជាត្រូវស្លៀកពាក់ខោអាវទូលាយ ? សំលៀកបំពាក់ដែលធ្វើតាមវិធីបង្ការរោគមានសណ្ឋានយ៉ាងណា ? សំពត់ត្បាញរបៀបយ៉ាងណា ដើម្បីឲ្យមានខ្យល់ចេញចូលស្រួល ? ស្បែកជើង មួកត្រូវរើសរកយ៉ាងដូចម្ដេច ? វេលាក្ដៅ វេលាល្ងាចត្រូវស្លៀកដូចម្ដេច ? ។

អាទិត្យទី ៤.– ចាប់រៀនជាថ្មីឡើងវិញ ។

## លោកនីតិ

## សម្រាប់គ្រប់ថ្នាក់

១– អំពីរបៀបតុលាការ

គ្រប់ប្រទេសទាំងអស់មានក្រុមតុលាការ សំរាប់ជំនុំជំរះកាត់សេចក្ដី ពិន័យ ឬ ធ្វើទោសជនណាដែលប្រព្រឹត្តបទល្មើសនឹងច្បាប់ ឬកើតហេតុទាស់ទែងនឹងគ្នា ។

ប្រទេសកម្ពុជាយើង របៀបតុលាការមានពីរបែបគឺ ក្រុមតុលាការខ្មែរ នឹងក្រុមតុលាការបារាំង ។ ក្រុមតុលាការខ្មែរជំនុំជំរះតែជាតិខ្មែរនឹងខ្មែរកើតវិវាទនឹងគ្នា បើខ្មែរនឹងជាតិដទៃឬជាតិដទៃដូចគ្នាកើតហេតុនឹងគ្នានោះ ត្រូវបែកខាងតុលាការបារាំងជំនុំជំរះវិញ ។

ក្រុមតុលាការខ្មែរមានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ( លោកយោមរាជ ) នាយកត្រួតត្រា ហើយក្រុមទាំងនោះមានច្រើនថ្នាក់ឬបែកឯទៀតផង ដូចសាលាលហុ សាលាដំបូង សាលាក្រុមបេទ សាលាឧទ្ធរណ៍ សាលាឧក្រិដ្ឋ នឹងសាលាវិនិច្ឆ័យ ។

សួរបោទ.– នៅប្រទេសយើងមានក្រុមតុលាការឬទេ ? ពីព្រោះអ្វីបានជាមានរបៀបតុលាការ ? បើខ្មែរនឹងខ្មែរទាស់ទែងគ្នា ត្រូវទៅប្ដឹងក្រសួងណាមុនដំបូង ? បើមេឃុំផ្សះផ្សាមិនព្រមជានឹងគ្នា ត្រូវទៅប្ដឹងឯណាទៀត? បើខ្មែរនឹងចិនឬនឹងយួនកើតវិវាទនឹងគ្នា ត្រូវទៅប្ដឹងឯណា? រដ្ឋមន្ត្រីណាដែលជានាយកលើក្រុមតុលាការទាំងអស់ ? មានមន្ទីរនៅត្រង់ណា? ចូររៀបរាប់សាលាជំនុំជំរះនៅប្រទេសកម្ពុជា ។ ល ។

សាលាលហុ

សាលាលហុមិនមែនគេតាំងនៅគ្រប់ខេត្តទេ ខេត្តខ្លះមាន ខ្លះគ្មាន ហើយច្រើនតាំងនៅកន្លែងណាដែលឆ្ងាយពីសាលាដំបូងផង មានចៅក្រមក្រសួងតុលាការម្នាក់ជាចាងហ្វាង ។ សាលាលហុមានអំណាចកាត់សេចក្ដីធ្វើទោសដាក់គុក កំណត់ពី ១ ថ្ងៃទៅដល់ ៥ ថ្ងៃយ៉ាងច្រើន បើគូក្ដីមិនសុខចិត្តនឹងប្ដឹងសុំទៅឧទ្ធរណ៍បាន ប៉ុន្តែបើទោសល្មើសនោះ ត្រូវពិន័យជាប្រាក់វិញ យ៉ាងតិច ៤០ សេន យ៉ាងច្រើន ៥ រៀលនោះ ឥតមានបើកផ្លូវឲ្យឧទ្ធរណ៍ទេ បើគូវិវាទមិនសុខចិត្តនឹងទោសលក់ពិន័យនេះ នឹងមានអំណាចប្ដឹងទៅសាលាវិនិច្ឆ័យបាន ។

បើរឿងណាជាបទរដ្ឋប្បវេណី គឺទាស់ទែងគេរ្ដិមត់កជាដើម ហើយ

ដម្លៃវត្ថុនោះ តិចពី ១០០រៀលចុះមក នោះសាលាលហុទើបកាត់សេចក្តីសម្រេចបានឥតទុកផ្លូវឧទ្ធរណ៍ បើគូក្តីមិនសុខចិត្តនឹងសុំទៅសាលាវិនិច្ឆ័យបាន ។ បើដម្លៃក្តីនោះ លើសពី ១០០រៀលឡើងទៅ ឬដម្លៃមិនបានច្បាស់ប្រាកដទេ ត្រូវកាត់សេចក្តីទុកផ្លូវឧទ្ធរណ៍ ។ ឯរឿងឧទ្ធរណ៍ដែលគូក្តីមិនសុខចិត្តនឹងសាលាលហុត្រូវធ្វើពាក្យឧទ្ធរណ៍ យកទៅប្តឹងសាលាដំបូងដែលសាលាលហុនោះត្រូវឡើង ។

## មេរៀនសង្ខេប.– សាលាលហុ

សាលាលហុសំរាប់ជំនុំជំរះបទលហុ គឺទោសល្មើសធ្វេសប្រហែសនឹងច្បាប់បញ្ញត្តិមានអំណាចកាត់សេចក្តីធ្វើទោសដាក់គុក ពី១ថ្ងៃទៅដល់៥ថ្ងៃយ៉ាងច្រើន ទុកផ្លូវឧទ្ធរណ៍ បើពិន័យជាប្រាក់វិញយ៉ាងតិចត្រឹម៤០-សេន យ៉ាងច្រើនត្រឹម៥រៀលឥតទុកផ្លូវឧទ្ធរណ៍ទេ ប៉ុន្តែបើនឹងប្តឹងទៅសាលាវិនិច្ឆ័យបាន ។

បើរឿងក្តីនោះចូលជាបទរដ្ឋប្បវេណីវិញមានដម្លៃមិនលើសពី ១០០រៀលទេ សាលាលហុកាត់សេចក្តីសម្រេចបានឥតមានទុកផ្លូវឧទ្ធរណ៍ តែបើដម្លៃក្តីនោះពុំបានច្បាស់ប្រាកដទេ ឬលើសពី ១០០រៀលឡើងទៅត្រូវកាត់សេចក្តីទុកផ្លូវឧទ្ធរណ៍ ។

សួរបោទ.– សាលាលហុច្រើនមានតាំងនៅកន្លែងណា ? សាលាលហុសំរាប់កាត់សេចក្ដីយ៉ាងណាខ្លះ? មានអំណាចកាត់សេចក្ដីដាក់គុកបានប៉ុន្មានថ្ងៃ ? ពិន័យប៉ុន្មានរៀល ? បើកាត់សេចក្ដីដាក់គុកហើយអ្នកជាប់ទោសមិនសុខចិត្តត្រូវប្ដឹងទៅឯណាទៀត ? ចុះបើមិនសុខចិត្តនឹងសាលានេះពិន័យលក់វិញត្រូវប្ដឹងទៅឯណាទៀត ? ។ល។

---

## មេសូត្រត់មាត់

(សំរាប់គ្រប់ថ្នាក់)

### ១.– សេចក្ដីទៀងត្រង់

ចូរអ្នកប្រព្រឹត្ត　　អំពើសុចរិត　　ទៀងត្រង់ប្រពៃ
សេចក្ដីប្រសើរ　　នេះមិនឲ្យភ័យ　　សុខសប្បាយក្រៃ
សម្បត្តិសឹងបាន ។　　កុំលាក់កុំលួច　　ទ្រព្យគេមិនរួច
នឹងគុកឡើយណា　　បើរើសឲ្យយក　　ដាក់ផ្ទះរាជការ
ទើបបានសុខសារ　　ឥតមានទោសពៃរ៍ ។

ពន្យល់ពាក្យ.– ប្រសើរ = ប្រពៃ ។ សារ = (ន) = បុណ្យ

ភ័ព្វ = សំណាង ។

## ២.- សិប្បិយការដែលកើតឡើងអំពីជាតិសត្វ អំពីសូត្រ

ឯជាតិខ្មែរយើងឥឡូវនេះ ច្រើនមានអ្នកចេះត្បាញប្រសើរ
ធ្វើអំពីសត្វល្អគ្រាន់បើ គេកប់អានប្រើផងឯទៀត ។
គេយកសូត្រមកធ្វើផាមួង ធ្វើហូលចាំងពួងទឹងព្រែលាត
ព្រែផ្កាក្រមាសារុងទៀត ឯហូលចងគាតមានគោមផង ។
ចំណែកឯអ្នកដែលធ្វើសូត្រ ខំប្រុតមនឲ្យនាងស៊ីហោង
ដល់នាងសម្បុរលឿងជាមួង គេក្រងមួសប្រើធ្វើសំពស់ ។
រួចចាប់ដង្កូវនាងដាក់ទៅ គ្នាខំប្រឹងនៅរាវហូស ។
ខំធ្វើសំបុកលើសំពស់ រាត់ទួរហ័សឆាប់ណាស់សារ ។
ទើបគេដាំទឹកថ្នាំងឲ្យពុះ យកសំបុកនោះដាក់ត្រៀបត្រា
រវៃបានសរសៃកាលណា ដោះហាលហើយសាយកទៅទុក ។

(ស្រង់យកពីកិច្ចសិក្សាបារាំង-ខ្មែរ គ.ស. ១៩៣៣)

ពន្យល់ពាក្យ.- សិប្បិយការ = មុខការដែលជាកំណើតនៃសិប្បៈ ។

ផាមួង = សំពត់សូត្រលាតផ្សេងៗ សម្រាប់ស្លៀក ។

គាត = សូត្រដែលចងរុំជាក្បាច់ដើម្បីទឹងធ្វើសំពត់ហូល ។

ថ្នាំង = ឆ្នាំងធំមានមាត់ធំធ្វើដោយដី ។

សា = (កិ) មូរឡើងវិញ, ដោះយកទៅទុកឡើងវិញ ។

សារ = (គុ) រឹងប៉ឹង, ខ្ជាប់ខ្ជួន ។

# ៣.– ការតំបាញ

ខ្មែរយើងត្បាញសំពត់នឹងកី　　សុទ្ធតែស្រី ៗ អ្នកត្បាញទេ
ឯប្រុសមិនបេះនៅទំនេរ　　រិះរកស៊ីផ្សេងទៅទៀត ។
អ្នកត្បាញអង្គុយលើក្ដារកី　　ចាប់ធ្នេញឈើវៃមិនឲ្យឃ្លាត
ជើងជាន់ឈើឈ្នាន់ទាំងពីរទៀត　　ដង្ករនោះឃ្លាតសរសៃហា ។
ហើយបោះត្រល់ទៅតាមចន្លោះ　　សរសៃអម្បោះចាក់ខ្វែងណា
អម្បោះអន្ទងនោះតែហា　　ចាក់របូកាលណាពេញធ្នេញដំ ។
លុះត្បាញបានល្បោះកាលណា　　ចុះធ្លាស្រាយខ្សែហើយមូរផ្សំ
មូរស្រេចកាលណាចុះរៀបចំ　　ហើយរំប្រឹងអង្គុយត្បាញទៀត ។
ដល់ត្បាញសំពត់ស្រេចកាលណា　　មានគេត្រូវការទិញព្រោងព្រាត
លក់អស់មួយកីតាំងត្បាញទៀត　　បែកញាតិទិញប្រើគ្រប់គ្នា ។

(ស្រង់យកពីកិច្ចសិក្សាបារាំង–ខ្មែរ គ.ស.១៩៣៣)

ពន្យល់ពាក្យ.– កី = ប្រដាប់សំរាប់ត្បាញ ។ ធ្នេញឈើ = ប្រទាសធ្វើដោយបន្ទោះល្អិតជាគ្រឿងតំបាញ ។ ឈើឈ្នាន់ = ប្រដាប់សំរាប់ជាន់ ។

ដង្ករ = ខ្សែអម្បោះឆ្មារសំរាប់ថ្ករតំបាញ ។ ល្បោះឬរបោះ = ឃ្លាតៗដាច់ពីគ្នា ។ ផ្សំ = គ្រឿងតំបាញ (បង្ហាញ)

## ៤ .— អំពីសត្វ

និយាយពីសត្វមានច្រើនណាស់ រូបខុសស្រឡះផ្សេងពីគ្នា
សត្វខ្លះសំរាប់ដឹកនានា ខ្លះជាជំនិះជិះតាមចិត្ត ។
ឯគោក្របីដំរីសេះ សត្វនេះត្រូវតែគួរអាណិត
ទោះប្រើយ៉ាងណាគ្នាមិនគិត តាមតែចិត្តទឹកប្រើប្រាស់វា ។
សត្វខ្លះយកសាច់ជាអាហារ ជ្រូកស្រុកសត្វសារគោមាន់ទា
គ្មានសំរាប់យកពង់វា សត្វខ្លះនៅនាទីព្រឹក្សា ។
មានប្រើសរមាំងតាំងឈ្លូសទ្រាយ ទន្សោងទន្សាយដំរីខ្លា
ពង្រូលបបកសំពោចស្ការ ពីងពាក់អាត្មានៅក្នុងព្រៃ ។
សត្វខ្លះរកស៊ីក្នុងទឹកផង ខ្ចៅខ្ចងឬណ្ដើកកន្លាយត្រី
ហើយមានសត្វល្អិតៗទៀតនៃ ស្រាំងរុយមូសច្រើនទៀតអើយ ។
(ស្រង់យកពីកិច្ចសិក្សាបាកាំង- ខ្មែរ គ.ស. ១៩៣៣)

ពន្យល់ពាក្យ.— ព្រឹក្សា = ឈើទាំងឡាយ ។ ទ្រាយ = ឈ្មោះម្រឹគ-ពួកឈ្លូស ។ កន្លាយ=សត្វទឹកមួយយ៉ាងពួកអណ្ដើក ។

# ៥- ភ្លើងអគ្គិសនី

ទីក្រុងស្រុកខ្មែរឥឡូវនេះ សប្បាយអឺម៉េះមានសព្វគ្រប់
មានអគ្គិសនីភ្លឺពេលយប់ ព្រលប់តាំងផ្ទះគ្មានសល់មួយ ។
មិនបាច់ចាក់ប្រេងដាក់ប្រផ្ទះ ស្រួលណាស់មិនបេះឲ្យមានព្រួយ
តែមួលខ្សែភ្លាមភ្លឺញួយ មិនព្រួយក្ដោលក្ដៀសដូចបន្ទុះ ។
គេរៀបតាមផ្លូវទីផ្សារធំ ជាទីប្រជុំមនុស្សកុញ្ញកុះ
ព្រលប់ឡើងហើយផ្ទះសក្បុស សាយសុសភ្លឺពេញលើផែនដី ។
កាលពីដើមពិបាកណាស់ តែចង់ភ្លឺច្បាស់តាំងប៉ូបព្រៃ
ខំដងដរ៍ទឹកមកឃ្លាតខ្លី រំពៃនឹងរកស្លឹកឈើផង ។
ហើយបានយកមករៀបក្រសោប ហើយក្ដោបយកខ្សែមករឹតបង
លុះបានបន្ទុះស្រេចជាម្ដង អុជទៅនោះហោងផ្សែងហុយទ្រុបៗ

(ស្រង់យកពីកិច្ចសិក្សាបារាំង - ខ្មែរ គ. ស. ១៩៣៤)

ពន្យល់ពាក្យ .- អគ្គិសនី= ភ្លើងរន្ទះ= ភ្លើងមេឃ ។ ក្ដៀស=កៀសទម្លាក់ (ក្ដៀសបន្ទុស) ។ កុញ្ញកុះ = ដេរដាស, ច្រើន ។ សក្បុស = គឺសសុទ្ធ, សណាស់ ។

រោងពុម្ពខ្មែរ